# កិច្ចសំភាសន៍របស់អ៊ីជួរ សុខចេង

កៈ អ្នកសំភាសន៍ឈ្មោះ ហេង សុជីវី ខៈ អ្នកដែលត្រូវគេសំភាសន៍ឈ្មោះ ជួរ សុខចេង

កៈ
ចាសអ៊ី!ជាដំបូងសុំជំរាបសួរ!!...ចាសអ៊ី!អ៊ី..ថ្ងៃនេះខ្ញុំនឹងមានឧកាសនឹងដើម្បីនឹងធ្វើសំភាសន៍ដល់អ៊ីផ្ទាល់ហើយខ្ញុំនឹងបានធ្វើការងារ១នេះស្មាគចិត្តអោយទៅដល់ខាងគំរោងរបស់សាលាBYU Hawaiនៅខាងសហរដ្ឋអាមេរិក។ហើយខាងសាលាគឺជាជំរូវដោយមានការសំភាសន៍ទៅដល់ប្រជាជនកម្ពុជាដែលគាត់មានអាយុចាប់ពី៣៥ឆ្នាំឡើងទៅដែលសួរអំពីជីវៈប្រវិត្តរបស់គាត់ពីពង្សប្រវិត្តបទពិសោធន៍ជីវិតរបស់គាត់នឹងដែលតាំងពីបទពិសោធន៍ជីវិតរបស់គាត់នឹងដែលគាត់បានធ្លាប់នឹងមានការឆ្លងកាត់តាំងពីមុននឹងមករហូតមកដល់ឥឡូវនឹងណាអ៊ី។

ខៈ ចាស!

កៈ
ចាសអ៊ី!ហើយចឹងថ្ងៃនេះនឹងខ្ញុំមានឧកាសដើម្បីនឹងធ្វើការសំភាសន៍ដល់អ៊ីនឹងចឹងផ្ទាល់នឹងតើអ៊ីនឹងអនុញ្ញាតដើម្បីនឹងអោយខ្ញុំធ្វើការសំភាសន៍ដល់អ៊ីដែរឬទេ?

ខៈ ចាសបាន!!

កៈ
ចាសអ៊ី!ចឹងការសំភាសន៍១នឹងនឹងត្រូវបានធ្វើឡើងនៅក្នុងថ្ងៃទី៣០ខែ៦ឆ្នាំ២០១៨យើងនេះផ្ទាល់ចឹងជាដំបូងឡើងនៃការសំភាសន៍នឹងសូមសួរដល់អ៊ីមួយសិនតើអ៊ីមានឈ្មោះអ្វីដែរ?

ខៈ ខ្ញុំមានឈ្មោះថា ជួរ សុខសេង។

កៈ ចាស!ចឹងឈ្មោះនឹងត្រូវជា១នឹងអត្តសញ្ញាប័ត្ររបស់អ៊ីដែរឬទេ?

ខៈ ត្រូវ!

កៈ ចុះអ៊ីមានឈ្មោះហៅក្រៅដែរឬទេ?

ខៈ អត់!

កៈ ចុះឈ្មោះរបស់អ៊ីជួរ សុខចេងនឹងអ៊ី !

ខ៖ ឈ្មោះ ជួរ សុខចេង។

ក៖ ចាស!ហើយចឹងឈ្មោះអីជួរសុចេងនឹងនរណាគេដែលបានដាក់ឈ្មោះនឹងអោយដល់អី?

ខ៖ ម៉ារបស់ខ្ញុំ!

ក៖ អូ..គាត់បានដាក់អោយអីហោះ?

ខ៖ ចាស!

ក៖ ហើយគាត់មានបានប្រាប់ដ៏អីថាតើឈ្មោះនឹងមានអត្ថន័យយ៉ាងណានោះទេ?

ខ៖ អូ..អត្ថន័យនឹងអី បងគាត់នឹង។ បងគាត់ដែលបានស្លាប់ទៅនឹងមានឈ្មោះថាសុខចេងនឹង។
ចឹងហើយនឹងគាត់នឹងបានយកឈ្មោះរបស់គាត់នឹងបានមកដាក់នៅឈ្មោះរបស់ខ្ញុំ។

ក៖ ហឺ!ដើម្បីនឹងនឹកចាំអំពីបងគាត់!

ខ៖ ចាស!ដើម្បីនឹងធ្វើការនឹកចាំអំពីប្រវិត្តរបស់បងគាត់ពីខាងម៉ារបស់ខ្ញុំនឹងមកវិញ។

ក៖
អូ...ដល់ពេលចឹងកាលនឹងគាត់នឹងមានបានប្រាប់អីដល់បងទេថាប្រវិត្តរបស់បងស្រីដែលត្រូវជាម្ដាយរបស់គាត់នឹងមានប្រវិត្តយ៉ាងម៉េចដែរបានជាគាត់នឹងបានដាក់ឈ្មោះនឹងចឹងដើម្បីនឹងធ្វើការចង់ចាំអំពីគាត់នឹងចឹង?

ខ៖
ការនឹងគាត់នឹងបានស្រលាញ់ម៉ារបស់ខ្ញុំនឹងអូសកាលនឹងគាត់នឹងបានស្រលាញ់បងរបស់គាត់ណាស់។

ក៖ ហឺ...

ខ៖
គាត់នឹងកាលនឹងបានស្រលាញ់ឈ្មោះរបស់បងគាត់ណាស់ហើយគាត់នឹងស្រលាញ់។ឈ្មោះនឹងចឹងហើយកាលនឹងបានជាគាត់នឹងបានទៅយកឈ្មោះនឹងដើម្បីមកដាក់នឹងអោយដល់ខ្ញុំនឹងតែម្ដងចឹងទៅកាលនឹង។

ក៖ ហឺ...

ខ៖
ពេលដែលបងគាត់នឹងបានស្លាប់ទៅនឹងកាលនឹងក៏គាត់នឹងបានយកឈ្មោះនឹង។កាលនឹងបងរបស់គាត់នឹងបានមកដាក់នៅនឹងឈ្មោះរបស់ខ្ញុំនឹង។

ក៖ ចាស!

ខ៖ ចាស!

ក៖ គាត់បានប្រាប់អីតែប៉ុណ្ណឹងនោះទេណ៎កាលនឹង?

ខ៖
ចាស!កាលនឹងគាត់នឹងបានប្រាប់ថាកាលនឹងគាត់នឹងបាននឹកឃើញអនុស្សាវរីយ៍ដែលបងរបស់គាត់នឹងបានស្រលាញ់គាត់នឹងមកចឹងណា។

ក៖អូ...

ខ៖
ដល់ចឹងបានជាគាត់នឹងបានយកឈ្មោះរបស់ខ្ញុំនឹងបានមកដាក់នៅក្នុងឈ្មោះរបស់ខ្ញុំនឹងបានមកដល់ឯសព្វថ្ងៃនឹងចឹងទៅ។

ក៖ អូ..ចឹងលោកឪពុកនឹងអ្នកម្ដាយរបស់អីនឹងគាត់មានឈ្មោះអ្វីគេដែរ?

ខ៖ ជួរ ហេងនឹង ដឹម សីន។

ក៖ អ្នកម្ដាយរបស់អីនឹងគាត់មានឈ្មោះអ្វីគេ?

ខ៖ គាត់មានឈ្មោះថា ដឹម សីន។

ក៖ ចាស!ហើយទៅដល់ពេលលោកឪពុកវិញ?

ខ៖ គាត់មានឈ្មោះថាជួរ ហេង។

ក៖ ចាស!ហើយចុះសព្វថ្ងៃនឹងគាត់មានអាយុបានប៉ុន្មានឆ្នាំហើយ?

ខ៖
ប៉ារបស់ខ្ញុំនឹងគាត់មានអាយុបានប្រហែលជា៥០ឆ្នាំនឹងជាងហើយប្រហែលជាងបាន៥៦ទៅ៥៧ហើយ។

ក៖ ហ៊ឺ..ចាស!ហើយសព្វថ្ងៃនឹងគាត់ទាំង២នាក់គឺរស់នៅជាមួយនឹងអ៊ីដែរ?

ខ៖ ចាស!គាត់បានរស់នៅជាមួយនឹងខ្ញុំ។

ក៖ ចាស!ហើយចុះអ៊ីសព្វថ្ងៃនឹងអ៊ីមានអាយុបានប៉ុន្មានឆ្នាំហើយ?

ខ៖ សព្វថ្ងៃនឹងខ្ញុំមានអាយុបាន៥០ឆ្នាំហើយ។

ក៖
អូ្..អ៊ីមានអាយុបាន៥០តាំងនៅក្នុងឆ្នាំថ្មីនឹងហើយហើយចុះអ៊ីមាននៅចាំថ្ងៃខែឆ្នាំកំណើតរបស់ខ្លួនឯងដែរឬទេ?

ខ៖ អត់ អត់មានបាននៅចាំនោះទេ។
ទាល់តែបានទៅមើលសំបុត្រនឹងក្រដាសរបស់ខ្ញុំហោសៗ!!

ក៖ ចុះអ៊ីមានអត្តសញ្ញាប័ត្រអត់ឬទេអ៊ី?

ខ៖ មាន..

ក៖ ចាស!ចឹងខ្ញុំអាចនឹងសុំថតអត្តសញ្ញាប័ត្ររបស់អ៊ីបានដែរឬទេ?

ខ៖ ចាស!

ក៖
ចាស!ចឹងពេលដែលចប់នូវការសំភាសន៍ពេលហើយទៅនឹងខ្ញុំសូមអត្តសញ្ញាប័ត្ររបស់អ៊ីនឹងដើម្បីនឹងធ្វើការសំភាសន៍បន្តិចចឹងណា?

ខ៖ ចាស!

ក៖
ចាស!ហើយអ៊ីអ៊ីទាក់ទងនឹងស្រុកកំណើតរបស់អ៊ីគឺនៅនឹងស្រុកកំណើតនៅទីនេះតែម្តងន៎?

ខ៖ ស្រុកកំណើតរបស់ខ្ញុំនឹងគឺនៅឯកោះដាច់នឹងតែម្តងនឹង។

ក៖ អ៊ឺ
..ដូចជាអ៊ីអាចនឹងធ្វើការបញ្ជាក់ទីតាំងបានដែលឬទេថាមានទីតាំងនៅឯណាដែលព្រោះថាពេលដែលបានសំភាសន៍ទៅនឹងខ្លាចអ្នកដែលគេនឹងបានស្តាប់នឹងគេអត់បានដឹងចឹងណា។

ថាអ៊ីនឹងមានទីតាំងនៅឯណា?

ខ៖ អ្នកស្លាប់ម៉េច?

ក៖
អត់ទេអ្នកដែលមានស្តាប់ដែលគាត់បានស្តាប់សំលេងរបស់អ៊ីនឹងដែរថាគាត់នឹងមិនបានដឹងថាអ៊ីមានទីតាំងនឹងនៅឯកន្លែងណាចឹង។
ចឹងហើយអ៊ីអាចនឹងធ្វើការបញ្ជាក់ទីតាំងនឹងអោយបានច្បាស់ដូចជាភូមិនឹងឃុំ!!

ខ៖ ភូមិនៅកោះដាច់នៅស្រុកមុខកំពូលនៅឯខេត្តកណ្តាល
នៅឯទីក្រុងភ្នំពេញនៅគេចាត់ចូលនៅខេត្តកណ្តាលដែលគាត់បានកាត់ចូលនៅម្តុំជ្រចង្វាយើងនឹង។

ក៖ ចាស!ត្រូវហើយអ៊ី!!

ខ៖ ចាស!

ក៖ ហើយចុះទាំងស្រុកកំណើតនឹងទីលំនៅបច្ចុប្បន្នអីនឹងគឺនៅនឹងឯនឹងតែម្តង?

ខ៖ ចាស!គឺបាននៅឯនឹង ពេលដែលបានដឹងក្តីមកនឹងគឺបាននៅឯនឹងតែម្តង។

ក៖ ចាស!ហើយអ៊ីសព្វថ្ងៃនឹងមានក្រុមគ្រួសារហើយឬនៅ?

ខ៖ ខ្ញុំមានហើយអូន។

ក៖ ស្វាមីរបស់អ៊ីគាត់មានឈ្មោះអ្វីដែរ?

ខ៖ គាត់មានឈ្មោះរដ្ឋអ៊ី គាត់មានឈ្មោះថា លឿ។

ក៖ គាត់មានឈ្មោះអីគេដែរអ៊ី?

ខ៖ គាត់មានឈ្មោះថាលឿ គាត់មាននាមត្រកូលរបស់គាត់នឹងមានឈ្មោះថា ឡាប លឿ។

ក៖ ហើយចុះអ៊ីសព្វថ្ងៃនឹងអ៊ីមានកូនចៅបានប៉ុន្មាននាក់ហើយ?

ខ៖ ខ្ញុំមានកូននឹងតែ១នាក់។

ក៖ គាត់មានឈ្មោះអីដែរទៅអ៊ី?

ខ៖ គាត់នឹងមានឈ្មោះថាស៊ីយា។

កៈ គាត់មានអាយុបានប៉ុន្នានឆ្នាំហើយអ៊ី?

ខៈ គាត់មានអាយុបាន៣ឆ្នាំហើយ។

កៈ គាត់ត្រឹមតែមានអាយុបាន៣ឆ្នាំទេ?

ខៈ ចាស!

កៈ ចុះអ៊ីគាត់បានចូលរៀនអ៊ីនឹងត្រឹមតែអាយុបាន៣ឆ្នាំនឹងចឹងនៅទេ។

ខៈ ចាស!

កៈ ហើយ

ខៈ គាត់នឹងនៅទេ

កៈ ចាសៗអ៊ីហើយគាត់គឺជាកូនប្រុសឬក៏ស្រីដែរអ៊ី?

ខៈ គាត់នឹងគឺកូនស្រី។

កៈ ហ៊ឺ..កូនស្រីទៀត!

ខៈ ចាស!

កៈ ហើយអ៊ីបានដាក់ឈ្មោះនឹងអោយដល់កូននឹងដោយសារមានមូលហេតុអ្វីគេដែរ?

ខៈ
ដោយសារឈ្មោះនឹងដោយគាត់អ្នកដែលបានដាក់អោយនឹងត្រូវជាលោកយាយប្ដីរបស់ខ្ញុំ។
កៈ ហ៊ឺ!

ខៈ គាត់នឹងត្រូវជាយាយប្ដីរបស់ខ្ញុំ។

កៈ ចាស!

ខៈ ចាស!ដល់ពេលហើយចឹងទៅគាត់នឹងបានយកឈ្មោះរបស់យាយនឹងយកមកដាក់វិញ។

កៈ អូ...

ខ៖ គាត់បានយកឈ្មោះនឹងយកមកដាក់វិញ។ គាត់បានយកមកដាក់ឈ្មោះនឹង កាលនឹងខ្ញុំនឹងចង់ដាក់ឈ្មោះនឹងថាស្រីពៅដែលនឹងតែគាត់នឹងវាមិនព្រម។ ចឹងហើយចឹងគាត់នឹងក៏បានដាក់ឈ្មោះយាយរបស់គាត់ទៅ។

ក៖ ចាស!

ខ៖ ចាសៗ

ក៖ ហើយទៅសព្វថ្ងៃនឹងអ៊ីមានមុខរបរជាអ្វីគេដែរ?

ខ៖ ខ្ញុំមានមុខរបរធ្វើចំការអីនឹងបានតែបន្តិចបន្តួចនឹង។

ក៖ អីមានធ្វើចំការដែរ?

ខ៖ មានចំការនឹងដូចជាចេកមានដូចជាពោតនឹងអីនឹងចឹងទៅណា ។(មានគេអ្នកដែលមកម៉ៅយកផ្លែខ្វិនសួរដល់អ៊ីហើយគាត់ក៏បានឆ្លើយឡើងថាអូឥឡូវនឹងវាបានធ្លាក់ទំពូកទៀតហើយរកតែអញនឹងរកពិភាសាគ្នានឹងមិនបានទេអី)

ក៖ អី!ឥឡូវអត់អីទេអ៊ី!......

ក៖ ចាស!ចឹងអ៊ីអាចនឹងរកប្រាប់ចំណូលនឹងបានប៉ុន្មានដែលជាមុនដំបូងនឹងសុំសួរអំពីការត្បាញ់សិន!

ខ៖ ចាស!ចំពោះអីចំការនឹងអីនឹងក្នុង១ថ្ងៃអីនឹងជួនកាលនឹងអាចរកបានតែ១៥០០០រៀលទេ។

(សំលេងអ៊ីគាត់បានគោះកី ក្ដេងៗៗៗ)

ខ៖ បើសិនជាយើងនឹងបានគិតទៅនឹងការត្បាញ់នេះវាអាចរកបានចំពោះ១ក្បិននឹងយើងអាចនឹងរកបានក្នុង១ក្បិននឹងបាន៣០០០០រៀល។ ចាសហើយទៅពេលដេលយើងនឹងបានត្បាញ់នឹងនៅក្នុង១ថ្ងៃនឹងយើងអាចនឹងរកមានត្បាញ់នឹងបានដល់តែ១សាលីនោះទេ។១សំពត់យើងនឹងនោះទេអានឹងវាបាន១៥០០០រៀល។ ហើយបើថា២ថ្ងៃអីនឹងបាន៣០០០០រៀលអីចឹងទៅ។

ក៖ ហឺ...

(សំលេងត្បាញ់)

ក៖ ចឹង១សាលីនឹងយ៉ាងម៉េចដែរទៅ?

ខ៖ ១សាលីនឹងវាបាន២ម៉េត្រដែលនឹងណា។

ក៖ចាស!

ខ៖ ចាស!បាន២ម៉េត្រនឹងចឹងទៅវាបានចំណូលនឹងបានក្នុងនឹងគឺ៥០០០រៀលចាស។

ក៖ ហឺ..!

ខ៖
ចាស!ហើយពេលដែលយើងយកវានឹងបានមកត្បាញ់នឹងវាបាន៣០០០រៀលដែលនឹងតែវាមិនទៅបានជាប់នោះទេ។

ក៖ ចាស!

ខ៖
វាមិនទៅបានជាប់លាប់នោះទៅព្រោះអីនឹងខ្ញុំពេលខ្លះទៅនឹងខ្ញុំត្រូវតែរវលទៅធ្វើចំការនឹងចឹងទៅ។

ក៖ ចឹងអីដូចថាក្នុង១ក្បិននឹងដែលត្រូវជា១សំពត់នឹងបានប៉ុន្មានថ្ងៃដែលបានហើយ?

ខ៖ ១សំពត់នឹងពេលដែលបាន១សំពត់នឹងវាបាន១ថ្ងៃនឹង។

ក៖ អូ..ចឹងវារាងលឿននឹងចឹងដែរនឹងចឹងហាសៗ?

ខ៖ ចាស!លឿនដែរហេសៗ!

ក៖
ចាស!ចឹងអីបាននឹងធ្វើការងារនឹងបានប៉ុន្មានម៉ោងដែរសំរាប់នឹងធ្វើការងារត្បាញ់១នឹងក្នុង១ថ្ងៃដែលអីបានចំណាយពេលសំរាប់វា?

ខ៖ តាំងពីព្រលឹមម៉ោង៧រហូតដល់ម៉ោង៩។

ក៖ ម៉ោង៩យប់?

ខ៖ ម៉ោង៩ថ្ងៃពេលព្រឹកនឹងធ្វើការងារនឹងតាំងពីម៉ោង៩ថ្ងៃនឹងបន្តរហូតដល់ម៉ោង៥។

កៈ ចាស!អ៊ីបានបន្តនឹងក្នុងការត្បាញ់នឹងរហូតមក?

ខៈ ចាស!យើងនឹងមានតែពេលទៅដាំបាយហូបនោះទេ
នឹងពេលដែលបានគេនអីនឹងហើយនឹងបានយើងនឹងបានមកត្បាញក្នុង១សំពត់នឹងចឹងទៅ។

កៈ ចាស!

(សំលេងអីគាត់បានត្បាញ់តីលឺសូរ កាំង១១)

ខៈ ចាស!

កៈ ចាស!ហើយចុះចំពោះឯចំការវិញចឹងណាអ៊ី
ចំការនឹងអ៊ីបានទៅធ្វើការងារនឹងចាប់ផ្តើមពីថ្ងៃណាដល់ថ្ងៃណាដែល
ហើយពេលដែលអ៊ីទៅធ្វើចំការចឹងអ៊ីឈ្លៀតពេលទៅយ៉ាងម៉េចចឹងទៅបើសិនជាអ៊ីជាប់ធ្វើការ
ងារនេះចឹង?

ខៈ អូ...ចំពោះការងារចំការនឹងយើងអាចនឹងក្រោកឡើងនៅម៉ោង៥ទៅម៉ោង៦នឹងចឹងទៅ។
ហើយថាពេលដែលបានទៅធ្វើការងារចំការនឹងដូចថាយើងនឹងអត់មានបានត្បាញ់នោះទេតែ
គ្រាន់តែថាពេលដែលយើងត្រូវទៅធ្វើការងារចំការយើងត្រូវរុំវានឹងទុកចោលនៅនឹងចឹងទៅហើ
យយើងទៅធ្វើការងារចំការប៉ុន្មានថ្ងៃអីចឹងទៅ។
ចាសទៅធ្វើព្រៃពោតចឹងទៅរឺក៏ទៅធ្វើការងារដាំពោតនឹងចឹងទៅណាហើយយើងនឹងបានត្បា
ញ់នឹងបានទុកចោលនឹងចឹងទៅហើយយើងឈ្លៀតទៅដាំវា១ថ្ងៃ២ថ្ងៃអីចឹងទៅ
ហើយទៅបានមកត្បាញអាចឹងវិញ។

កៈ
ចាស!ហើយចឹងដល់ពេលដែលបានប៉ុន្មានថ្ងៃចឹងទៅហើយពេលដែលយើងនឹងត្រូវទៅមើលនឹ
ងគឺវាបានផលតែម្តង។

ខៈ
ចាស!ពេលដែលយើងនឹងទៅមើលនឹងគឺថាវាបានផលតែម្តងហើយយើងនឹងដាក់ជ្រុមជ្រោយ
វាចឹងទៅ។

កៈ ចាស!

ខៈ ចាស!ជ្រុមជ្រួយវាចឹងទៅដាក់ជីអីដល់ពេលចឹងទៅ!

កៈ ចាស!ចឹងចំការនឹងវាគឺនៅឆ្ងាយពីទីនេះដែរឬទេ?

ខៈ ចំការនឹងវានៅទល់មុននឹងទីនេះដែរនឹង។

កៈ អូ..ប្រហែលជាបានប៉ុន្មានហិតាដែរទៅដែលបានដាក់ដាំនឹង?

ខៈ ដីនឹងប្រហែលជាក្បាលប្រហែលជា១៦ហើយទទឹងនឹងប្រហែលជា៥០០ជាង។

កៈ អីបានដាំអ្វីគេខ្លះដែរ?

ខៈ
ហឺបានដាក់ដាំចេកនឹងហើយនឹងពោតអីចឹងខ្លះនឹងដែរហើយពេលដែលបានលក់នឹងបានតែប្រហែលជា៣០០០០រៀលអីនឹង ហើយយើងកាប់នឹងឡើងហូរខ្លាញ់អស់ហើយ!

កៈ ហូរខ្លាញ់?

ខៈ បែកញើសយើងនឹងណាហាៗ!

កៈ អូ..ដោយសារតែហាត់ពេក!

ខៈ ចាស!

កៈ ព្រោះអីត្រូវច្រម៉ៀសវា!

ខៈ បានតែ១៣០០០រៀលនឹងអីនឹងត្រូវតែកាប់យកទៅដល់អោយគេនឹងទៅដល់ផ្ទះ។

កៈ អូ..ចឹងគេមិនបានមកយកដល់កន្លែងទេហ៎?

ខៈ អត់ទេយើងកាប់យកទៅអោយគេនឹងទៅដល់កន្លែង។

កៈ ចុះថ្ងៃសីលអីនឹងខ្ញុំបានលឺថាគេបានយកវាមកលក់នៅនឹងមុខផ្ទះហេសអី?

ខៈ ថ្ងៃសីលអីនឹងយើងអាចលក់បានប្រហែលជា៣ទៅ៤ស្និតអីនឹង។
តែបើថាវាមានច្រើនអីនឹងដឹងតែត្រូវចោលហើយ។
និយាយទៅនឹងគឺវាអត់សូវដាច់តែម្តងគឺលក់បានតែ១ទៅ២អីទេហើយទៅកាលពីស្បៀលនឹងលក់អត់មានបាន១ស្និតអីផងចឹងហើយនឹងខ្ញុំនឹងក៏បានបកវាដាក់ហាល។
ពេលខ្លះចឹងទៅក៏បានបកដាក់ហាលអីនឹងបានផ្ញើទៅអោយអ្នកស្រែអ្នកអីនឹងចឹងទៅ។

កៈ ចាស!

ខ៖ អានឹងនៅលើដំបូងនឹងអានឹងវាសុទ្ធតែចេកដែលនឹងយកទៅដាក់ហាល។

ក៖ អូ...

ខ៖
គេខ្លះនឹងគេបានអោយខ្ញុំនឹងបានដាក់ហាលដែលនឹងតែគ្រាន់តែថាខ្ញុំនឹងវាគេអោយហាល៤០ទៅ៥០គីឡូនឹងគឺចឹងណាតែខ្ញុំនឹងវាបានតែបកដាក់ហាលទៅនឹងយកទៅអោយប្អូននឹងទេ។ព្រោះអីគ្នានឹងវាលំបាករកអីសំរាប់នឹងហូបចឹងណាព្រោះអីគេនឹងនឹងវានៅឯស្រុកស្រែនឹងណា។

ក៖ ចាស!

ខ៖
គ្នានឹងវាជាអ្នកដែលធ្វើការហើយចឹងវានឹងពេលខ្លះទៅនឹងវាអត់សូវមានពេលចឹងហើយខ្ញុំនឹងក៏បានបកដាក់ហាលសំរាប់វានឹងចឹងទៅណា។ហើយទៅក៏បានយកទៅអោយនឹងចឹងទៅ។

ក៖ អូ..ចាសអ៊ី!

ខ៖ ចាស!

ក៖
ហើយទៅសំរាប់ចំការនឹងដែរអ៊ីបានចេះបច្ចេកទេស១នឹងគេបានប្រាប់អ៊ីឬក៏ចេះមកពីណាមក?

ខ៖
កាលនឹងខ្ញុំនឹងបានរៀនអំពីឪពុកម្តាយនឹងដែលគាត់នឹងបានបង្រៀនចឹងហើយខ្ញុំនឹងបានចេះពីគាត់នឹងមកវិញ។

ក៖ អូ..ចឹងពីម្តាយនឹងឪពុករបស់អ៊ីទេ?

ខ៖ ចាស!ខ្ញុំចេះនឹងពីគាត់មកទេកាលនឹង។
កាលត្បាញ់នឹងខ្ញុំនឹងបានទៅមើលគាត់ធ្វើនឹងបានជួយគាត់នឹងមករហូតនឹង។

ក៖ អូ...ចឹងអ៊ីបានចេះតគ្នានឹងមករហូតមក។

ខ៖ ចាស!បានចេះពីគាត់នឹងរហូតតមកដល់ខ្ញុំនឹងវិញ។

ក៖ ហឹស!

ខ៖ ចាស!!

ក៖ ចាស!ហើយចឹងកាលពីមុននឹងតើអ៊ីមានបានធ្លាប់ធ្វើការងារអ្វីក្រៅពីនឹងដែរឬទេអ៊ីណុំ?

ខ៖ កាលពីមុននឹងមកនឹងខ្ញុំនឹងបានចូលទៅធ្វើការងារនៅឯរោងចក្រនឹងបានចំនួន១ឆ្នាំ ទៅហើយចឹងវានឹងរាងប្រវិត្តនឹងឡើងរាងជួចត់ពេកនឹងវាលំបាកដូចថាអ៊ីប្រខែនឹងបានតែ១២០ដុល្លានោះទេកាលនៅជំនាន់នឹងដែលខ្ញុំនឹងបានធ្វើការងារនឹងកាលជំនាន់ដែលខ្ញុំបានធ្វើនឹងនោះ។ ហើយបើសិនជាគិតទៅលើផ្ទះជួលនឹងទឹកថ្លៃពេទ្យអីនឹងកាលនឹងវាមិនគ្រាន់នោះទេ វាមានដូចថា អង្គត្រីសាច់អីនឹង វាមិនបានទេ
ចឹងហើយកាលនឹងយើងនឹងវាបានដោះស្រាយទៅនឹងវាមិនបានរួចទេកាលនឹង។
ហើយចឹងទៅពេលដេលយើងនឹងបាននឹកឃើញថាវានឹងវាមិនបានរួចនឹងចឹងកាលនឹងក៏យើងនឹងចាប់ផ្តើមមកធ្វើខាងត្បាញ់អីនឹងនៅឯផ្ទះរបស់យើងនឹងវិញ។
ព្រោះបើសិនជាទៅធ្វើការងារនៅឯរោងចក្រនឹងយើងវាត្រូវចំនាយច្រើនណាស់វាគិតទៅនឹងវាអត់មានបាននៅសល់អីនោះទេចឹងហើយបានថាមកធ្វើការងារត្បាញ់នឹងវិញចឹងទៅដើម្បីនឹងធ្វើការងារត្បាញ់ទៅនឹងវារាងថាគ្រាន់បើជាងនោះគឺយើងមិនត្រូវចំណាយទៅលើទឹកភ្លើងនឹងថ្លៃផ្ទះអីនឹងចឹង។

ក៖ ហឺ...ចាស!

ខ៖ ចាស!ចឹងទៅខ្ញុំនឹងក៏សំរាចចិត្តនឹងដើម្បីនឹងទៅត្បាញ់នឹងវិញ!

ក៖ ចាស!វានឹងបានគ្រាន់នឹងនៅសល់លុយអីខ្លះដែរព្រោះអីយើងនៅក្នុងផ្ទះ។

ខ៖
ចាស!នឹងហើយយើងគ្រាន់ថាបាននៅសល់អីនឹងតិចចឹងទៅគ្រាន់បានសល់ហើយណាមួយយើងនឹងវាបាននៅជួបជុំនឹងម្តាយឪពុករបស់យើងនឹងផង។

ក៖ ចាស!

ខ៖
ហើយបើថាពេលដែលយើងនឹងបានធ្វើការងារនឹងទាល់តែយើងនឹងបានធ្វើការងារថែមម៉ោងនឹងចឹងទៅបានយើងនឹងបាននៅសល់លុយដើម្បីនឹងយកលុយនឹងយកមកអោយដល់មកម្តាយ។

ក៖ ហឺ..!ចាស!

ខ៖ ហើយបើថាយើងនឹងបានធ្វើការងារនឹងថែមម៉ោង!

(គាត់បាននិយាយទៅសួរអ្នកដែលគេបានមកទិញផ្លែខ្វិតរបស់គាត់ដែលបាននឹងដើរចូលមកថា អែងប៉េះបានប៉ុន្មានផ្លូននឹង? គេឆ្លើយឡើងនឹងថា មិនបានដឹងប៉ុន្មាននោះទេព្រោះអីអត់ទាន់បានរាប់ផងនឹង)

ក៖ អូ..អ៊ីប៉េះផ្លែខ្វិនមែនទេអ៊ី!

ខ៖ នឹងហើយ

ក៖ អូ..ចឹងខ្វិតខាងក្រោយនឹងចឹងក៏អាចនឹងប៉ះលក់ដែរនឹង?

ខ៖ ចាស!

ក៖ វាប៉េះបានតែ១រដូវឬទេ? ឬក៏អាចនឹងប៉េះបានប៉ុន្មានដែរ?

ខ៖ វាប៉េះបានឹងតែ១រដូវនឹងទេ!

ក៖ រដូវរបស់វានឹងគឺខែនឹងមែនអ៊ី?

ខ៖ រដូវរបស់វានឹងគឺនៅខែនឹងហើយគឺខែនឹងគឺនឹងវាកំពុងតែពេញផ្លែហើយ។

ក៖ ហើយទៅវាបានអស់ទៅវិញនឹងបាននៅក្នុងខែណាដែរទៅអ៊ី?

ខ៖ អស់ទៅវិញនឹងនៅក្នុងខែភាគច្រើននឹងខ្ញុំនឹងវាមិនសូវបានជាចាំនោះទេហើយដូចជាកាលរដូវវានឹង ដូចជា អឺ និយាយទៅនឹងរដូវកាលរបស់វានឹងក្នុង១ឆ្នាំនឹងវាមានផ្លែបាន៣ដង។ អានឹងយើងគិតថាយើងបានប្រមូលផ្លែរបស់វានឹងណាបាន៣ដងនឹងក្នុង១ឆ្នាំហើយចឹងក្នុង១ឆ្នាំនឹងវាបាន៣ដង។

ក៖ គ្រាន់តែថាវាបានរាងបានផ្លែនឹងវាបានច្រើនដែរនឹង!

ខ៖ នឹងហើយវានឹងបានផ្លែនឹងវាបានរាងច្រើនដែរនឹង។ ចាសកាលដែលវាបានផ្លែមកនឹងបានរាងធំនឹងខ្ញុំនឹងបានឡើងទៅលើដើមនឹងបេះដោយខ្លួនឯងនឹងណា។

ក៖ ចាស!

ខ៖
ចាស!អានឹងខ្ញុំនឹងបានឡើងណាខ្ញុំនឹងបានឡើងទៅដើម្បីនឹងប៉េះដល់គេព្រោះអីនឹងពេលដែលខ្ញុំនឹងបានអោយប្តីខ្ញុំនឹងទៅគាត់មិនអាចនឹងឡើងបានទេព្រោះអីគាត់គឺទៅធ្វើការងារនឹងនៅឯភ្នំពេញ។ ព្រោះអីនៅក្នុង១ខែនឹងគេបានអោយគាត់នឹងបានឈប់តែ១ថ្ងៃនោះទេ។

ក៖ អូ....គាត់បានធ្វើការងារនឹងខាងផ្នែកអីដែរទៅអ៊ី?

ខ៖
ហឺ...គាត់នឹងបានធ្វើការងារនឹងវារាងបានធម្មតានឹងជាគ្រាន់តែថាវាជាធម្មតានោះទេដែលថាមនុស្សនឹងយើងវាស៊ីឈ្នួលអោយគេចឹងហើយយើងនឹងវាគ្មានថ្ងៃសៅរ៍ថ្ងៃអាទិត្យនោះទេ។

ក៖ចាស!

ខ៖ គាត់នឹងបានធ្វើការងារនឹងនៅជា១នឹងចិនណា។

ក៖ ចាស!!

ខ៖
ចាស!គាត់នឹងមិនសូវបានជួបនឹងប្រពន្ធនឹងកូននោះទេពេលដែលបានចេញមកម្តងៗនឹងដូចចេញពីក្នុងគុកនឹងចឹង។ រាលថ្ងៃនឹងខ្ញុំនឹងអាណិតប្តីខ្ញុំណាស់
អាណិតប្តីនឹងខ្ញុំមិនចង់អោយគាត់នឹងទៅធ្វើនោះទេតែគ្រាន់តែថាបើសិនមិនអោយគាត់នឹងបានទៅធ្វើទេនឹងចឹងពេលដែលយើងនឹងបាននៅជុំគ្នានឹងខ្លាចតែយើងអត់មានអីសំរាប់នឹងហូប។

ក៖
គាត់មានបានប្រាប់អ៊ីទេថាពេលដែលគាត់នឹងធ្វើការងារនៅឯថៅកែលចិននឹងតើគាត់បានធ្វើការងារផ្នែកអីដែរ?

ខ៖ គាត់នឹងបានទៅស៊ីឈ្នួលអោយគេបានទៅយាមផ្ទះនឹងអោយដល់គេណា។
តែគ្រាន់តែថាខាងថៅកែលចិនគេនឹងគេបានរកស៊ីនឹងរាងធំជុំអីដែរនឹងចឹងណា។គ្រាន់តែយើងនឹងបានទៅនៅនឹងចឹងគ្រាន់តែយើងនឹងបានទៅថែរសួនអីនឹងបានបន្តិចបន្តួចអីនឹងនោះទេ។
ចឹងយើងនឹងគ្រាន់តែជាអ្នកដែលបានទៅថែរក្សាសួននឹងចឹងហើយយើងវាអត់បានអស់ថ្លៃសួននឹងអីចឹងណា។ វាគ្រាន់តែថាថ្លៃទឹកថ្លៃភ្លើងនឹងយើងវាមិនអស់ទេ
ហើយចឹងប្រាក់ខែរបស់យើងនឹង២០០ដុល្លានឹងដឹងតែនៅសល់។

តែគ្រាន់តែថារាលថ្ងៃនឹងវាបានអស់នឹងដោយសារតែប្ដីរបស់ខ្ញុំនឹងគាត់បានទៅហូបបារីអីនឹងចឹងណាជូនកាលនឹងគាត់បានយកលុយនឹងទៅហូបបារីនឹងកាហ្វេអីនឹងចឹងទៅ។

ក៖ ចុះគាត់អាចនឹងផ្ញើលុយមកផ្ទះនឹងបានលុយប៉ុន្មានដែរ?

ខ៖
ក្នុង១ខែនឹងគាត់បានផ្ញើរបានតែ១៥០ដុល្លានឹងទេគ្រាន់តែគាត់នឹងពេលខ្លះចឹងទៅបានដកអស់៥០ដុល្លាអីចឹងទៅដើម្បីនឹងយកទៅទិញបារីអីនឹងជក់ចឹងទៅព្រោះអីនឹងគាត់នឹងជាអ្នកដែលជក់បារី។

ក៖ ចាស!

ខ៖
ចាសគាត់នឹងបានជក់បារីនឹងកាហ្វេអីនឹងចឹងទៅហើយចិនគេនឹងគេបានអោយយើងនឹងបានហូបបាយចំណីអីនឹងនៅក្នុងនឹងនោះទេ។
គ្រាន់តែថាបារីអីនឹងយើងជក់អីនឹងចឹងទៅគេនឹងមិនមានបានគិតអីនឹងសំរាប់នឹងអោយដល់យើងនឹងទេយើងនឹងអ្នកដែលរកនឹងខ្លួនឯនឹងនោះទេ។ ចាសគ្រាន់តែចឹង!

ក៖ ចាសៗត្រូវហើយ!
ចឹងមានន័យគាត់បានទៅចាំផ្ទះហើយគាត់ជាអ្នកដែលថៃសួនហើយនឹងគាត់គឺជាសន្តិសុខទៀតនឹង?

ខ៖ ចាស!

ក៖ ហើយអីដល់ពេលចឹងតើអីមានបានធ្លាប់បានទៅលេងគាត់នៅឯណោះដែលឬទេ?

ខ៖ ខ្ញុំនឹងដូចថាពេលដែលបាន១ខែអីនឹងចឹងខ្ញុំបានទៅលេងដល់គាត់អីនឹងបាន១ដងដែរនឹង។
ចឹងខ្ញុំនឹងបានកំណត់ថានៅក្នុង១ខែនឹងខ្ញុំត្រូវទៅលេងគាត់នឹងបាន១ដង។
ហើយចឹងពេលខ្លះចឹងទៅក្នុង១ខែនឹងខ្ញុំអាចនឹងទៅលេងគាត់នឹងបាន១ដងទៅ២ដងអីនឹងដែរចឹងទៅ។

ក៖ ជាពិសេសនឹងទៅពេលដែលគាត់នឹងបានបើកលុយនឹងតែម្ដង!!ហេសៗៗៗ!!

ខ៖
ចាស!ទៅនឹងជាពិសេសនឹងគឺខ្ញុំនឹងបានទៅនៅពេលដែលខ្ញុំនឹងបានដឹងថាគាត់នឹងបានបើក

លុយនឹងហើយព្រោះអីគឺថាដោយសារតែពេលដែលបានទៅនឹងម្ដងៗនឹងគឺថាខ្ញុំនឹងវាត្រូវចំណាយសាហុយនឹងច្រើនដែរចឹងហើយពេលទៅគឺត្រូវតែបានប្រាក់មកវិញ
ព្រោះអីនឹងទៅគឺយើងនឹងដឹងតែថាត្រូវតែបានលុយ។

ក៖ ចាស!!

ខ៖នឹងហើយដល់ពេលដែលយើងនឹងទៅអត់បានលុយនឹងវាបានខាតនឹងសាហុយ
ហើយខាតតឹងសាហុយនឹងហើយនឹងវាបានខាតទៅនឹងការងារនឹងទៀតឯណោះ។

ក៖ ចាស!ត្រូវហើយ!ហោសៗៗ
នឹងហើយត្រូវតែបានលុយនឹងមកខ្លះចឹងហើយដើម្បីនឹងយកមកអោយកូនអីគាត់បានចាយ!

ខ៖ នឹងហើយទៅនឹងសំខាន់អោយតែបានលុយ!

ក៖ ចាស!

ខ៖ ប្ដីម៉េចៗសិនទៅ!!ហោសៗ!

ក៖ ចាស!ហោសៗ ចាសចឹងរកសន្សំដើម្បីនឹងរកវាបានតក់ៗនឹងសិនចឹង។

ខ៖ ចាស!!

ក៖ ចាស!ហើយចឹងទៅគាត់មានដែលបានឈឺទេអី?

ខ៖
គាត់នឹងបានឈឺដែរនឹងគ្រាន់តែថាគាត់នឹងបានឈឺវាបន្តិចបន្តួចទេគ្រាន់តែថាវាជាជំងឺរាងក្ដៅនឹងរងារអីនឹងតែបន្តិចនោះទេ។ គាត់នឹងដូចថាវាមិនដែលនឹងបានសូវជាឈឺធ្ងន់នឹងចឹងណា!!

ក៖ ចាស!ហើយចុះចំណែកអ៊ីវិញ?

ខ៖ ចំណែកឯខ្ញុំនឹងដូចថាវាជួនឈឺនឹងជួននឹងវាអត់ចឹង។
ហើយជួនទៅនឹងវាភ្លមៗទៅនឹងដូចជាពេលល្ងាចមិញនឹងចឹងទៅ។
ពេលល្ងាចមិញនឹងវាត្បូញអីនឹងដូចទៅនឹងធម្មតានឹងតែគ្រាន់តែថាពេលដែលល្ងាចមិញនឹងពេលដែលបានមកដល់ផ្ទះវិញនឹងដូចថាដូចជារាងលេសលាសក្ដៅនឹងឡើងប្រើរងារអីនឹងចឹងទៅតែមួយភ្លែកនឹង។

ក៖ ចឹងមានតែអ៊ីចាញ់ទេអីអ៊ី?

ខ៖ អត់ដឹងទេ តែគ្រាន់តែថាអាណឹងយើងថាវានឹងចាញ់នឹងក៏ថាបានវាមិនចាញ់នឹងក៏ថាបានដែល។ គ្រាន់តែថារដូវនឹងវាមកវាមិនបានទៀងអីនឹងចឹងទៅណាហើយចឹងបានជាខ្ញុំនឹងបានថារដូវរបស់ខ្ញុំនឹងវានឹងអត់ស្រូវបានមកនឹងជាទាងនឹងនោះទេ។ ហើយបើថាវានឹងចាញ់នឹងក៏ខ្ញុំនឹងក៏បានអរដែលព្រោះអីនឹងបានកូននឹងមាន១ទៀត។

ក៖ ហាសនឹងហើយបើបាន១ទៀតនឹងគ្រាន់មាន២នាក់នឹងគ្រាន់បានមានគ្នា។

ខ៖ ចាស!គ្រាន់បានមានគ្នា ចាសចឹងទៅពេលដែលបានមាននឹងជាអីនឹងគ្រាន់ថាយើងនឹងបាន១ទៀដែរ។

ក៖ ចាសៗ

ខ៖ ចាស!

ក៖ ហឹសៗហើយអីពេលដែលអីបានសំរាលកូនទី១នឹងតើអីបានសំរាលនៅឯណាដែរទៅអីនៅឯពេទ្ររបស់យើងនឹងឬក៏នៅឯណាដែរទៅ?

ខ៖ នៅឯពេទ្យជប៉ុន។

ក៖ នៅឯណាវិញទៅអី?

ខ៖ នៅឯពេទ្យជប៉ុននៅឯភ្នំពេញនឹង។

ក៖ អូ….

ខ៖ ចាសចឹងកាលនឹងនោះពេលដែលខ្ញុំនឹងបានឈឺពោះនឹងគឺខ្ញុំនឹងបានឈឺពោះនឹងវាអត់បានកើតនឹងណាចឹងហើយនឹង(មានគេមកសួរដល់គាត់ថាតើវាលែងប៉េះហើយឬអី? អីបានឆ្លើយថាវានឹងបានទៅណាឯណោះបាត់ទៅហើយវាលែងប៉ែះហើយ)។

ពេលដែលយើងនឹងបានឈឺពោះនៅឯពេទ្យធំនឹងគេមិនបានអោយយើងនឹងទៅឯណានោះទេកាលនឹងគេបានអោយយើងនឹងបានដើរទៅណាកាលនឹង។

ក៖ ចាស!!

ខ៖ ចាស!គេនឹងបានអោយយើងនឹងបានដើរទៅនឹងហើយដល់ពេលរួចទៅនឹង។ យើងនឹងបានឈឺៗនឹងយើងឈឺៗនឹងវាអត់មានបានកើតនោះទេ។ ដល់ពេលដែលយើងនឹងទៅដល់ពេទ្យកាម៉ែតហើយនឹងកាលនឹងយើងបានទៅហើយនឹងគេថាយើងនឹងអត់មានទឹកថ្លោះ។ ចឹងហើយនឹងក៏ត្រូវវះកាត់ចឹងទៅ។

ក៖ ចាស!

ខ៖ ហើយពេលដែលបានវះកាត់នឹងកាលនឹងអត់មានលុយអត់មានកាក់អីនោះទេកាលនឹងនោះ។ ពេលនឹងដូចថាមានថៅកែលចិនៗនឹងគេបានជួយឧបត្ថមនឹងអោយមកដល់ខ្ញុំនឹងទេកាលនឹង។ ថៅកែលរបស់ខ្ញុំនឹងពេលនឹងមានថៅកែលរបស់ខ្ញុំមេគេនឹង១០០ដុល្លាហើយទៅមិត្តភក្តិគាត់នឹងមានម្នាក់ៗនឹង៥០ទៅ២០ដុល្លានឹងចឹងហើយចឹងគេនឹងចេះតែសន្សំមកនឹងចឹងទៅ។ ដល់ពេលចឹងទៅពេលដែលកូនរបស់ខ្ញុំនឹងវាបានកើតបានប៉ុន្មានខែនឹងចឹងខ្ញុំនឹងបានទៅធ្វើការងារនឹងអោយដល់គាត់។ កាលនឹងខ្ញុំនឹងបានធ្វើខាងចុងភៅនឹងហើយទៅកាលនឹងខ្ញុំនឹងបានទៅឈ្លោះគ្នានឹងជាមួយនឹងចិននឹងដែលជាភ្ញៀវរបស់គាត់នឹងដែលបានមកលេងចឹងណា។

ក៖ អឺហ៎អឺបានឈ្មោះជាមួយភ្ញៀវរបស់គាត់?

ខ៖ ចាស!!

ក៖ អឿសៗ

ខ៖ ដោយសារភ្ញៀវរបស់គាត់នឹងដូចថាមិនបានគោរពយើងនឹងជាខ្មែរនឹងចឹងណាហើយចឹងទៅបានជាយើងនឹងជាខ្មែរនឹងចឹងគាត់បានលើខ្វះនឹងរំលងក្បាលរបស់យើងនឹងចឹងហើយប៉ះដល់យើងនឹងចឹងហើយចឹងគាត់អត់មានបានមកសុំទោសដល់យើងនោះទេ។

ក៖ ដល់ពេលចឹង....

គ៖ អីគេ?

ក៖អាខ្វះឆាយើងនឹង។

គ៖ អូ...

ក៖
ពេលនឹងយើងនឹងបានយកវាមកឆាបន្លែអីនឹងនៅថ្ងៃនឹងភ្ញៀវនឹងបានមកនឹងចឹងចំនួន៣៦នាក់ៗចឹងហើយធ្វើយ៉ាងម៉េចត្រូវតែច្នៃមុខម្ហូបហើយទៅមុខម្ហូបចិននឹងដូចថាអត់មានអីដូចជាយើងនឹងឯណា។ ចាសដូចថាពេលដែលគ្រាប់៧នាក់នឹងធ្វើយ៉ាងម៉េចអោយបានគ្រាប់នឹង។

ក៖ ហឺ..

ខ៖
ហើយកាលនឹងធ្វើយ៉ាងណាអោយបានហើយវានឹងបានធ្វើម្ហូបនឹងតែ១កូនចានៗរបស់វានឹងសំឡ។ ហើយទៅពេលថ្ងៃនឹងឆាក្តីនឹងជាចុងក្រោយនឹងអាក្តីគេឃូននឹងយើងនឹងណា។

ក៖ ហឺ...

ខ៖ បានដាក់ឆានៅពេលចុងក្រោយយើងនឹង។
ស្រាប់តែវានឹងបានមកលើកខ្វះនឹងបានមករំលងមកលើក្បាលយើង ។

ក៖ ហឺគាត់...

ខ៖ គាត់នឹងមានបានចេះនិយាយភាសាខ្មែរនឹងខ្លះៗដែរចឹងហើយចឹងខ្ញុំថាអ៊ី
អ៊ីធ្វើចឹងសមដែរឬក៏អត់?

ក៖ ហឺ..

ខ៖ អ៊ីឯធ្វើចឹងបានគោរពខ្ញុំនឹងជាខ្មែរដែរឬអត់?

ក៖ ហឺ..!

ខ៖ មានបានន័យថាអ៊ីឯងនឹងចិនចិនជាន់ខ្មែរមែន?

ក៖ ហឺ..!

ខ៖
គ្រាន់តែសួរគាត់នឹងបានតែប៉ុណ្ណឹងគាត់បានហៅអ្នកបកប្រែមកដើម្បីនឹងមកប្រមានថាសំដីរបស់យើងនឹងឆ្លើយ។ ដល់ពេលដែលថាយើងនឹងឆ្លីយទៅនឹងក៏ខ្ញុំចេះតែទៅហើយពេលនឹង។

ក៖ ហឺសៗ

ខ៖
ចឹងទៅកន្លែងណាដែលវានឹងបានស្តាប់បានទៅចឹងកាលនឹងវាស្តាប់បានទៅតែនៅកន្លែងខ្លះនឹងវាស្តាប់មិនបាននឹងវាបានទៅសួរដល់អ្នកបកប្រែ។
ហើយទៅដូចថាពេលដែលអ្នកបកប្រែនឹងត្រូវតែឆ្លើយអោយស្រួលប្រយ័ត្នតែបកនឹងមិនស្រួលនឹងប្រយ័ត្ននឹងមានបញ្ហាជា១នឹងខ្ញុំហើយបើថាបកប្រែអត់កើតនោះទេពេលនឹងខ្ញុំនឹងហៅប្អូនខ្ញុំនឹងមកបកប្រែ។

ក៖ ហឺ...!

ខ៖ ព្រោះអីនឹងខ្ញុំក៏មានប្អូនរបស់ខ្ញុំនឹងវាក៏ចេះដែលមិនមែនចេះតែអ្នកឯងនោះទេ។

ក៖
ហើយទៅមានឯណាបកប្រែអោយខ្ញុំនឹងពេលដែលខ្ញុំនឹងបានជេអីនឹងវាបកប្រែអោយទៅទាំងអស់។
ដល់ពេលខ្ញុំនឹងបានចាក់ចេញមកនឹងចឹងកាលនឹងគាត់បានហៅខ្ញុំនឹងបានទៅធ្វើការងារនឹងវិញដែរតែខ្ញុំនឹងអត់ទៅ។
ព្រោះអីកាលនឹងគេនឹងបានកាន់ជើងដល់ភ្ញៀវរបស់គេពេលនឹងកេបានកាន់ជើងដល់ភ្ញៀវរបស់គេកាលដែរពីមុនដំបូងនឹង។កាលនឹងគេបានកាន់ដើរថាអោយយើងនឹងថាខ្លាំងៗ.....

ក៖ ភ្ញៀវនឹងកាលនឹងវាមានរឿងអីបានជាគាត់នឹងបានលើកខ្វះនឹងចឹង?

ខ៖ ភ្ញៀវនឹងកាលនឹងវាថាដូចជាបានយកមុនយកមាត់ដែរ។

ក៖ អូ...!

ខ៖
ចាស!និយាយទៅនឹងបើសិនជាយើងនឹងជាភ្ញៀវពេលនឹងយើងចាំនឹងចូលទៅក្នុងតុហើយស៊ីទៅ!

ក៖ ចាស!នឹងហើយ!

ខ៖ បើខ្មែរយើងនឹងកាលនឹងយើងថាស៊ីតែម្តងទៅវាបានឆាប់នឹងចប់។

ក៖ ចាស!ត្រូវហើយ!

ខ៖
តែចំពោះភ្ញៀវម្នាក់នឹងពេលដែលមកនឹងដូចថាអញនឹងជាអ្នកដែលស្លឆ្ងាញ់ហើយថាគេនឹងជាអ្នកដែលចេះចឹងម៉ងណា!

ក៖ ហឺ

ខ៖ហើយមើលមកយើងនឹងថាយើងនឹងវាមិនបានចេះទៅដល់គេចឹងណា។
ហើយដល់ពេលចឹងទៅលើចុះលើដាក់អីនឹងចឹងហើយក៏បានត្រូវក្បាលខ្ញុំ។
ខ្ញុំណាពេលដែលបាននៅជា១នឹងថៅកែនឹងបាន១ឆ្នាំហើយអត់ដែរគាត់ប្រើបញ្ជាអោយខ្ញុំនឹងធ្វើអានេះទៅធ្វើអានោះអត់ទេណា។
ហើយពេលដែលវានឹងមកនឹងវាបញ្ជាក្បាលយើងនឹងដូចជាយើងនឹងជាសំរាមនឹងចឹងណា។

ក៖ហឺ...

ខ៖
ហើយយើងនឹងកាលនឹងមិនមែននឹងស៊ីប្រាក់ខែនឹងពីភ្ញៀវនឹងឯណាកាលនឹងយើងនឹងបានស៊ីប្រាក់ខែនឹងពីថៅកែយើងនឹងទេ។
ហើយចឹងបានថាពេលដែលវានឹងមកថាអោយយើងនឹងពេលនឹងបើថាជាថៅកែរបស់យើងនឹងមកថាអោយយើងនឹងយើងវាមិនសូវជាឈឺចាប់នោះទេ។
ហើយនេះមានសិទ្ធត្រឹមតែជាភ្ញៀវនឹង។

ក៖ ចាស!គាត់គ្រាន់តែជាភ្ញៀវហើយគ្រាន់តែគាត់នឹងបានមកលេងនឹងហាស។

ខ៖
ចាស!គាត់គ្រាន់តែមកលេងនឹងហើយចឹងមកត្រួតក្បាលរបស់ខ្ញុំនឹងចឹងគឺអត់បាននោះទេ។
ខ្ញុំថាបើខ្មែរណាបានតែចំពោះខ្ញុំនឹងខ្ញុំមិនអោយអ្នកឯងមកជាន់ក្បាលរបស់ខ្ញុំនោះទេ។

ក៖ ចាស!ត្រូវហើយ!

ខ៖
ខ្ញុំនឹងបានមកធ្វើការអោយអ្នកឯងនឹងណាក៏មិនមែនទៅសូមអោយអ្នកឯងនឹងដាចសាច់ដែរ។

ក៖ ចាស!ត្រូវហើយៗ

ខ៖
ខ្ញុំនឹងវាមិនអត់មានតំលៃនោះទេបើអ្នកឯងនឹងអត់មានអោយប្រាក់ខែខ្ញុំក៏ខ្ញុំនឹងអត់ធ្វើការងារជា១នឹងអ្នកឯងដែរអានឹងខ្ញុំនឹងនិយាយចឹង។ដំពេល....

ក៖ អានឹងយើងកុំអោយគេមើលងាយ!!

ខ៖ចាសខ្ញុំនឹងមិនបានអោយគេនឹងមកមើលងាយនោះទេ ចាស។
ខ្ញុំថាពេលដែលខ្ញុំនឹងមកនឹងខ្ញុំក៏មិនបាននឹងមកសុំអង្វរអ្នកឯងមកធ្វើការងារនឹងដែរ។
គឺអ្នកឯងទេដែលទៅរកខ្ញុំ...

ក៖ គឺគាត់ការនឹងធ្វើអត់មានបានគោរពសិទ្ធរបស់យើង។

ខ៖
ចាស!គាត់អត់មានបានថាគោរពយើងនឹងជាខ្មែរនោះទេគាត់អត់បានគោរពយើងហើយមើលងាយដល់ខ្មែរយើងនឹងពេកហាស។
ហើយកាលនឹងថៅកែរបស់ខ្ញុំនឹងកាលនឹងគាត់នឹងមិនបានដឹងដំពេលដែលគាត់នឹងអត់បានដឹងចឹងទៅ គាត់ក៏ចឹងក៏ចេះតែអឺ គាត់បានចេះតែថាអោយយើងនឹងចឹងទៅណា
ហើយចឹងគាត់បាននិយាយចេះមួយចុសមួយនឹងចឹងទៅហើយចឹងខ្ញុំនឹងក៏បានថាអឺ
ពាក្យសំដីនឹងអឺនិយាយនឹងអត់ល្អទេហើយខ្ញុំបានចូលមើលអីនឹងអឺថាអោយដល់ខ្ញុំអីនឹងអត់មានបានថានឹងចូលដល់ត្រចៀករបស់ខ្ញុំនោះទេ។
ខ្ញុំនឹងក៏ជាខ្មែរ១នាក់ដែរហើយខ្ញុំនឹងក៏ជាមនុស្សលោកនឹងមួយម្នាក់ដែរ។

ក៖ ហឺ..

ខ៖
ហើយអឺនឹងក៏ជាមនុស្សលោកនឹង១ដែរតើហើយចឹងដល់ពេលនិយាយថាចឹងគឺអត់ល្អនោះទេ។អឺមិត្តភក្តិរបស់អឺងណោះបានល្អខ្ញុំនឹងធ្វើអ្វីនឹងអត់បានល្អនោះទេ។
ដល់ពេលរួចចឹងទៅភ្ញៀវនឹងក៏បានឈប់មកនឹងរហូតទៅដល់ពេលដែលបានឈ្លោះគ្នាជា១នឹងខ្ញុំនឹងហើយនឹងមក។

ក៖ ហឺ...

ខ៖
ដល់ពេលរួចចឹងទៅថៅកែស្រីនឹងគាត់ក៏បានចង់អោយខ្ញុំនឹងបានទៅធ្វើការងារនៅឯនុងវិញ។

ដល់ចឹងខ្ញុំបានប្រាប់គាត់ថាបើចង់អោយខ្ញុំនឹងបានទៅធ្វើការងារនៅឯនុងវិញនឹងលុះត្រាតែអ្នកដែលគេបានឈ្លោះគ្នាជា១នឹងខ្ញុំនឹងគេនឹងកុំចូលផ្ទះនឹង។
ពេលដែលបានចូលនៅក្នុងផ្ទះនឹងចឹងទៅដល់ពេលដែលខ្ញុំនឹងបានឃើញមុខនឹងចឹងនៅក្នុងចិត្តរបស់ខ្ញុំនឹងដូចថាដូចជាភ្លើងនឹងវាឆេះ។ខ្ញុំនឹងបាននិយាយទៅវិញនឹងចឹង....

ក៖ ចាស!

ខ៖ ដូចថាក្នុងចិត្តរបស់ខ្ញុំនឹងដូចជាភ្លើងឆេះ
ទៅហើយថាដល់ពេលដែលកុំអោយមើលឃើញមុននឹងអត់អីនោះទេតែបើថាអោយខ្ញុំនឹងបានឃើញមុននឹងអត់អីនោះតែបើថាបានឃើញហើយនឹងនោះគឺថានៅក្នុងចិត្តរបស់ខ្ញុំនឹងវាដូចជាភ្លើងនឹងបានឆេះ។

ក៖ ចាស!

ខ៖
ចាស!វានឹងបានឆេះហើយវាឆេះទៅនឹងអត់មានមូលហេតុទេម៉ោងប៉ុន្មាននឹងក៏វាឆេះដែរ។អោយតែថាឃើញស្មាណាវាឆេះឡើងស្មានឹង។

ក៖ អូដូចថាអ៊ីកាលនឹងខឹងពេក។
ហើយចឹងកាលនឹងគាត់អត់មានបានសុំទោសដ៏អ៊ីអីនឹងដែរឬទេ?

ខ៖ អត់ទេណានៅតែសំដីតែថាខ្ញុំនឹងសំដីថ្លើយនឹងសំដីនឹងថ្លសទៀត។
គាត់បានថាខ្ញុំនឹងមកស៊ីឈ្នួលនឹងអោយដល់គេទេតែដូចថានៅតែសំដីនឹងថ្លស។ហើយពេលនឹងខ្ញុំនឹងក៏បានឆ្លើយឡើងថាអ៊ីខ្ញុំបានស៊ីឈ្នួលអោយដល់អ្នកឯងមែនតែថាស៊ីឈ្នួលរបស់ខ្ញុំនឹងគឺស៊ីឈ្នួលដោយមានតំលៃមិនមែនទៅស៊ីឈ្នួលអ្នកឯទៅកាន់កាដួយនឹងក្តអ្នកឯងនឹងនោមនោះទេ។ខ្ញុំនឹងបាននិយាយចឹង។

ក៖ ហ៎....ហើយចឹងពេលនឹងអ៊ីបានធ្វើការងារនឹងយូរហើយឬនៅជាមួយនឹងចិននឹង?

ខ៖ ធ្វើការងារជា១នឹងចិននឹងខ្ញុំបានធ្វើការងាររយៈពេលបាន២ឆ្នាំហើយ។

ក៖ ចាស!

ខ៖
ធ្វើការងារនឹងធ្វើតាំងពីកូនរបស់ខ្ញុំនឹងវាបានកើតបាន៦ខែនឹងខ្ញុំបានទៅធ្វើការងារនឹងជា១នឹងគាត់នឹង។

ក៖ ចាស !

ខ៖ ចាស!

ក៖ ចុះអ៊ីចេះធ្វើមុខម្ហូបអីគេខ្លះដែរទៅអ៊ី?

ខ៖ ខ្ញុំនឹងបានចេះធ្វើមុខម្ហូបនឹងចេះធ្វើដូចជាឆាដូចជាខអីចឹងទុកអោយគាត់អីចឹងទៅណា។ពេលខ្លះទៅគាត់ចង់ខឆ្អឹងជ្រូកអីនឹងចឹងទៅគាត់បានអោយធ្វើនឹងចឹងទៅ។កាលនឹងគេខនឹងវាមិនមែនដូចជាខ្មែរនោះទេគេខនឹងគ្រាន់តែចាក់ស្រាសយើងនឹងណា បំពង់ខ្ទឹមសយើងហើយចាក់អាស្រាសនឹងប្រហែលជា១តិចចឹងទៅហើយគាត់អត់មានបានប្រើស្កអីនោះទេគាត់នឹងបានតែប្រើតែអំបិលនោះទេហើយនឹងទឹករបស់គេនឹង។ ហើយគេនឹងអត់មានប្រើរបស់កំប៉ិកកំប៉ុកអីនោះទេ។ដូចជាស្ករនឹងប៊ីចេងអីនឹងដូចយើងនោះទេគេបានប្រើតែអំបិលនឹងតែម្តង។

ក៖ អូ..គេប្រើតែអំបិលទេ?

ខ៖ ចាស!គេប្រើតែអំបិលនឹងទឹកគេទឹកស្រាគេនៅក្នុងនឹងតែម្តងនោះ។ ទឹកស្រារបស់គេនឹងពេលដែលគេបានប្រើដូចថាអីនឹងបានតិចតួចអីនឹងគេបានប្រើតែអានឹង។ ដូចថាគេនឹងប្រើខ្ទឹមប៊ីចេងអីនឹងដូចជាយើងនឹងគឺអត់មាននោះទេ។ ហើយចឹងពេលនឹងសូម្បីតែខ្ញុំនឹងបានស្លម្លម្ហូរយើងនឹងពេលដែលយើងនឹងជ្រុមប្រហុកនោះពេលដែលបានផុមខ្លិននឹងដល់គាត់។ គាត់ថារបស់ដែលស្អុយនឹងអត់ញ៉ាំនោះទេ។ ហើយបើថាបើសិនជាយើងនឹងចង់ស្លហូបសំរាប់ខ្លួនយើងនឹងគាត់បានលួចប៊ីចេងយើងនឹងទៅបោះចោល។

ក៖ហឺៗ

ខ៖
គាត់ថាខ្មែរយើងនឹងចឹងហូបប៊ីចេងនឹងបានចេះតែពុកឆ្អឹង។អានឹងគាត់បានអោយផ្តល់ជាយោបល់នឹងក៏ល្អដែលនឹង។
តែគ្រាន់តែយើងនឹងថាប្រហែលជាទឹកនៅក្នុង១ឆ្នាំនឹងពេលដែលមានទឹកនឹងប្រហែលជាបាន

៣លីត្រនឹងហើយខ្ញុំនឹងបានដាក់ប៊ីចេងនឹងប្រហែលជា១ចុងសាបព្រានោះទេ។រាល់ថ្ងៃនឹងខ្ញុំជាអ្នកដែលបានហូបប៊ីចេងច្រើនតែឥឡូវនឹងខ្ញុំបានកាត់បន្ថយ១ខែនឹងអស់តែ១កញ្ចប់នោះទេតែដល់ពេលឥឡូវនឹង៣ខែបានអស់១កញ្ចប់។

ក៖ ចាសដោយសារតែយើងនឹងបានដឹងទៅ!!

ខ៖ ដល់ពេលដែលយើងនឹងបានដឹងទៅនឹងយើងបានកាត់បន្ថយនឹងទៅតាមគាត់ចឹងណា។

ក៖ ហឺ...

ខ៖
តែដល់ពេលដែលបានទៅនៅជា១នឹងគាត់បានរៀងយូរដែលទៅចឹងយើងនឹងក៏ចេះតែបានផ្លូក់សំលរបស់គាត់។
យើងនឹងបានធ្លាប់ហូបសំលរបស់គាត់នឹងបានយូរដែរនឹងចឹងទៅហើយក៏យូរៗដល់ពេលដែលបានមកហូបសំលរបស់ខ្លួនឯងនឹងហូបនឹងលលែងចង់នឹងដឹងអស់ទៅហើយទៅជាប្រៃអីទៅអស់ហើយ។

ក៖ ហឹសៗ

ខ៖ ទៅជាបានប្រៃអីនឹងទៅជាឡើងផ្លូវអីនឹងអស់ទៅហើយ។ វាដោយសារតែចឹង!

ក៖ ចឹងកាលនឹងគាត់នឹងបានបង្រៀនដល់អីនឹងផ្ទាល់តែម្តង?

ខ៖
ចាស!កាលនឹងគាត់បានមកបង្រៀនដល់យើងកាលនឹងគាត់អត់មានថាអោយនរណាគេមកដើម្បីនឹងបង្រៀនដល់យើងនឹងគឺអត់មានទេកាលនឹង
ចឹងពេលនឹងថាគាត់នឹងជាអ្នកដែលបង្រៀននឹងក៏ថាបានដែលព្រោះអីពេលដែលយើងនឹងបានទៅមុនដំបូងនឹងគាត់បានចាប់ផ្តើមអោយយើងនឹងមើលទៅគាត់ថាយើងគាត់នឹងបាននឹងដាក់អីគេខ្លះអីគេខ្លះចឹងណា។

ក៖ ចាស!

ខ៖ ហើយដល់ពេលខ្លះនឹងដល់ពេលខ្លះគាត់បានធ្វើគីលឈីអីនឹងចឹងទៅណា។
ហើយពេលដែលគាត់បានទៅទិញគីមឈីអីនឹងចឹងទៅកាត់នឹងក៏បានអោយយើងនឹងរៀនធ្វើវាដោយខ្លួនឯងចឹងទៅ។

ហើយទៅយយើងនឹងក៏ធ្វើវាចឹងទៅយើងបានយកវាទៅច្របាច់ទឹកដាក់អំបិលអីនឹងចឹងទៅហើយយកវានឹងទៅដាក់ហាលអីចឹងទៅណា។
ចាសគាត់បានបង្រៀនយើងនឹងចឹងទៅហើយយើងនឹងបានចេះចឹងទៅគាត់នឹងបានបន្ទាយអោយយើងនឹងធ្វើទៅហើយគាត់មុនដំបូងនឹងគាត់បានអោយប្រាក់ខែដល់ខ្ញុំនឹងតែ១២០ដុល្លានោះទេ។

កៈ ហឹ....

ខៈ
អានឹងសំរាប់១ខែដំបូងនឹងបានតែ១១០ដុល្លាទេហើយចឹងវាសំលាប់នឹងកូនរបស់ខ្ញុំនឹងដែលវានឹងតឹមតែបាន៩ខែនោះទេហើយយើងបានចូលទៅធ្វើការងារជា១នឹងគាត់។

កៈ ហឹ...!

ខៈ ខ្ញុំនឹងបានធ្វើនៅនឹងទាល់តែកូនរបស់ខ្ញុំនឹងបាន៣ឆ្នាំនឹងជាង។

កៈហឹ..

ខៈ
ហើយកាលនឹងខ្ញុំនឹងកុំអីមិនទៅចេញនោះផងកុំតែរឿងឈ្លោះគ្នានឹងកុំអីខ្ញុំមិនទៅចេញនោះទេ។ ខ្ញុំនឹងនៅធ្វើការងារនឹងនៅជា១នឹងរហូតហើយ។

កៈ ចាស
...ចាសហើយជីវិតរបស់អ៊ីនឹងបានតស៊ូតាំងពីមុននឹងមករហូតមកដល់ពេលឥឡូវនឹងចឹងហើយអ៊ីមានដែលធ្លាប់បានឆ្លងកាត់នៅក្នុងសម័យពពតដែរឬទេ?

ខៈ អត់ទេ!

កៈ អត់បានកើតទាន់ទេណោកាលនឹង?

ខៈ អត់បានកើតទាន់នោះទេ!!

កៈ កាលនឹងចឹងអ៊ីមានបានធ្លាប់ឪពុកនឹងម្តាយរបស់អ៊ីប្រាប់អ៊ីអំពីជំនាន់ពពតនឹងអត់អ៊ី?

ខៈ
ធ្លាប់តើកាលនឹងគាត់បានប្រាប់ថាកាលនៅជំនាន់ពពតនឹងកាលនឹងវាបានលំបាកអីនឹងចឹងទៅណាកាលនឹងនោះ។

កាលនឹងវាមិនសូវបានរបោះរបរអីសំរាប់នឹងបានហូបចុកអីនោះទេកាលនឹងហើយមានបបរអី នឹងកាលនឹងគាត់គេចែកអោយបបរនឹង១វែកៗម្នាក់ចឹងទៅណា។
ហើយចឹងកាលនឹងគាត់ចេះតែនិយាយទៅនឹងចឹងហើយពេលនឹងមើលទៅថាកាលនឹងចាស់ៗ ពីជំនាន់នឹងវាលំបាកពេកចឹងទៅណាហើយចឹងកាលពីជំនាន់នឹងក៏បាននឹងឃើញហើយសួរមកកខ្លួនឯង។
ពេលនឹងបានសួរខ្លួនឯងនឹងថាកាលពីជមាន់នឹងបើសិនជាឯងនឹងបានកើតនៅក្នុងជំនាន់នឹងដែរនឹងប្រហែលជាងប់ហើយមើលទៅ។

ក៖ហឹស...

ខ៖
កាលនឹងវាចេះតែមើលឃើញនឹងវែងឆ្ងាយហើយកាលនឹងហើយកាលនឹងចាស់កាលពីជំនាន់ នឹងនោះគេថាបានងាប់នឹងបានងាប់វាមិនជាតិចដែរ។ ចាស
ចាសកាលនៅជំនាន់នឹងគាត់បានងាប់ទៅនឹងច្រើនណាស់ហើយកាលនឹងយើងនឹងវាមិនបាន នឹងកើតទាន់គាត់នឹងទៅដែរទេ។

ក៖
ចាស!ហើយចឹងអ៊ីកាលនឹងអ៊ីមានបទពិសោធន៏ដែលលំបាកលំបាកអីគេខ្លះដែលវាជាការលំបាកនៅក្នុងជីវិតរបស់អ៊ីនឹងចឹងតើអ៊ីមានជួបការលំបាកអីគេខ្លះនៅក្នុងជីវិតរបស់អ៊ីដែលវាបាន ធ្វើអោយអ៊ីនឹងចង់ចាំអត់នឹងភ្លេចបានសោះឡើយ?

ខ៖
កាលនឹងខ្ញុំនឹងបានចង់ចាំថាកាលតាំងពីខ្ញុំនឹងបានប្តីហើយនឹងខ្ញុំនៅមិនទាន់បានស្រណុកបាន សប្បាយណាងចឹង។ព្រោះអីមើលកាលនឹងពេលដែលខ្ញុំនឹងបានចូលរៀននឹងពេលខ្ញុំមុននឹង ទៅរៀនខ្ញុំបានទៅវែកទឹក
ដាក់ក្នុងពាងសិនទុកអោយម្តាយសិនសំរាប់នឹងទុកអោយគាត់នឹងបានដាំបាយហើយបានទៅ រៀន។
ហើយកាលនឹងពេលដេលបានទៅរៀននឹងខ្ញុំនឹងវាមិនបានទៅរៀនឹងទាន់គេនោះទេកាលនឹង ពេលដែលបានទៅនឹងគឺទៅយឺតជាងគេហើយចឹងគ្រូនឹងអោយខ្ញុំនឹងលន់ជង្គង់នឹងនៅលើសំបកខ្នុលនឹងក៏មានហើយពេលដែលខ្ញុំបាននឹកឃើញឡើងនឹងវាបានឈឺចាប់។
ហើយកាលនឹងទៅរៀននឹងកាលនឹងយើងនឹងអត់សូវបានទៅរៀនច្រើននោះទេព្រោះអីកាលនឹ

ងយើងនឹងបាននឹកឃើញថាយើងនឹងជាបងគេនឹងណាចាស។នឹកឃើញហើយនឹងបានឈឺចាប់ថាវាមិនបានដូចជាក្មេងឥឡូ
វនឹងដែលវាមានទឹកភ្លើងអីនឹងដល់ផ្ទះហើយគេបានរៀនសូត្រស្រួល
លំបាកតែខ្ញុំនឹងវាវេទនាណាស់ ។

ក៖ ហឺ..

ខ៖
កាលនឹងពេលដែលខ្ញុំនឹងមុននឹងទៅរៀននឹងត្រូវតែដើបឡើងនឹងពីប្រលឹមដើម្បីនឹងរែកទឹករែកអី
នឹងទំរាំតែបានទៅរៀននឹងហើយដល់ពេលដែលបានដឹងក្តីនឹងឡើងលោកប៉ារបស់ខ្ញុំនឹងគាត់បានធ្វើចង្កៀងលក់ហើយពេលនឹងគាត់បានរកវ៉ៃខ្ញុំព្រោះអីនឹងកាលនឹងខ្ញុំធ្វើអីនឹងក៏ខុសធ្វើអ្វីក៏ខុសដែរ។ដំពេលចឹងហើយកាលនឹងឪពុករបស់ខ្ញុំនឹងគាត់បានធ្វើបាបដល់ខ្ញុំណាស់គាត់បានវៃដល់ខ្ញុំហើយទៅកាលនឹងគាត់នឹងកាចពេលដែលបានថាខឹងកូននឹងហើយគឺវ៉ៃ
ដលល់ពេលហើយដល់ទៅខ្ញុំនឹងរៀនអត់ចូលទៅនឹងរហូតដល់ពេលដែលខ្ញុំនឹងបានចាប់យកសៀវភៅមកមើលនឹងគាត់បានប្រាប់អោយខ្ញុំនឹងទាញយកសៀវភៅមកមើលនឹងចឹងណា។
គាត់បានស្រែពីផ្ទះ១ដល់ផ្ទះ១។ ដល់ពេលចឹងទៅរៀននឹងវាអត់ចូលទេ
ដល់ពេលដែលបានរៀននឹងវាអត់មានបានចូលចឹងទៅហើយក៏យើងនឹងវាបានរៀនតិចអត់បានរៀនអីនឹងចឹងទៅ។
ចឹងបានជាគេនឹងវាជាន់ឆ្លីដល់យើងនឹងហើយពេលដែលយើងនឹងបាននឹកឃើញឡើងនឹងខ្ញុំវាបានឈឺចាប់ណាស់។
ព្រោះអីវាពេលនឹងថាសំដីរបស់យើងនឹងវាមិនទៅបានរៀនសូត្រចេះដឹងនឹងដូចគេ។

ក៖ ហឺ..

ខ៖
ហើយពេលដែលបានប្តីនឹងហើយនឹងក៏នៅតែពិបាកវាគ្មានទៅបានសប្បាយដូចជានោះទេរហូតមានប្តីនឹងចឹងតាំងពីអត់មានប្តីរហូតដល់មានប្តី។
នឹកឃើញឡើងនឹងគឺវាលំបាកនឹងមករហូត។

កៈ
ចាស!ហើយចុះអ៊ីកាលដែលបានការជាមួយនឹងអ៊ីប្រុសដែលគាត់ត្រូវជាស្វាមីរបស់អ៊ីនឹងតើគាត់បានស្រលាញ់គ្នាឬក៏ពុកម្តាយគាត់ជាអ្នកដែលបានរៀបចំអោយ?

ខៈ
កាលនឹងខ្ញុំស្រលាញ់គ្នាកាលនឹងមិនមែនឪពុកម្តាយនឹងគាត់ជាអ្នកដែលបានរៀបចំអោយនឹងនោះទេកាលនឹងនោះ ។កាលនឹងគឺខ្ញុំនឹងបានស្រលាញ់គ្នា។

កៈ ហឺ..ចាស!

ខៈ ចាស!

កៈ ហឺ..ចឹងកាលនឹងបានរៀបការស្របច្បាប់តែអីហេស៎?

ខៈ
អត់នោះទេកាលនឹងនោះសូម្បីតែម្តាយឪពុកកាលនឹងគាត់ថារៀបអោយនឹងគាត់អត់បាននឹងរៀបអោយដែលការនឹងគឺបានរៀបដោយខ្លួនឯងនឹងតែម្តង។ចាស
ដល់ពេលដែលខ្ញុំនឹងបានចាក់ចេញពីផ្ទះនឹងទៅគឺខ្ញុំនឹងបានរៀបការនឹងដោយខ្លួនឯងទេកាលនឹង។

កៈ ហឺ...

ខៈ
ប្រវិត្តរបស់ខ្ញុំនឹងបានស្រលាញ់គ្នានឹងកាលនឹងឪពុកម្តាយនឹងគាត់មិនមែនជាអ្នកដែលបានរៀបអោយនោះទេកាលនឹងគឺយើងបានរៀបដោយខ្លួនឯង។
ព្រោះអីកាលនឹងគាត់នឹងបានកាត់ការពូកខ្ញុំនឹងចោលទៅណាកាលនឹង ។
ដល់ពេលនឹងយើងនឹងមានប្រវិត្តឈឺចាប់ហើយបានតស៊ូទៅធ្វើការងារនៅឯរោងចក្រ
ពេលដែលបានចេញពីរោងចក្រមកនឹងបានជួបនឹងថៅកែជាជនជាតិចិននឹងបានគេយកមកធ្វើការជាមួយនឹង
ដល់ដែលគេនឹងបានជួយអោយថ្លៃរះកូនរះអីនឹងចឹងរហូតដល់ពេលដែលខ្ញុំនឹងបានមានកូនមានថៅហើយកាលនឹងវាអស់លុយពីខ្លួន។

កៈ ហឺ!

ខ៖
ចឹងកាលនឹងវានឹងជាប្រវិត្តឈឺចាប់របស់ខ្ញុំនឹងដែលថាកាលមុននឹងខ្ញុំវាមិនចង់នឹងសំភាសន៍នោះទេតែឥឡូវនឹងខ្ញុំសំភាសន៍បាត់។ ព្រោះអីខ្ញុំនឹងទប់ទឹកភ្នែកអត់បាននោះទេ។

ក៖ អឺ!ដោយសារតែអ៊ីមានប្រវិត្តតស៊ូអស្ចារ្យមែនទែន!

ខ៖ ហឺ!ខ្ញុំនឹងបានខំប្រឹងនឹងឡើងអស់ពីខ្លួនហើយបង ខ្ញុំនឹងបានប្រឹងឡើងខ្សោះខ្លួន។

ក៖ ចាស!
ហើយសង្ឃឹមថាការសំភាសន៍មួយនឹងនឹងបានជួយដល់កូនចៅជំនាន់ក្រោយដែលគេបានស្តាប់ហើយគេបានស្តាប់សំលេងរបស់អ៊ី។
ហើយគេនឹងស្តាប់សំលេងមួយនឹងជាពិសេសកូនរបស់អ៊ីនឹងណាចឹងហើយទៅគេនឹងមានមោទនភាពចំពោះម្តាយរបស់គេដែលបានខំប្រឹងមក...

ខ៖ ចាស!

ក៖ ដែលអ៊ីបានខំប្រឹងដើម្បីនឹងចិញ្ចឹមគាត់!!
ហើយចឹងសំរាប់អ៊ីតើអ៊ីមានគំរោងអីទៀតសំរាប់ទុកអោយកូនៗដែរឬទេ?

ខ៖
ខ្ញុំចង់អោយកូននឹងកុំអោយវាល្ងង់ដូចខ្ញុំនឹងចឹងណា។ខ្ញុំចង់អោយកូននឹងបានរៀនបានចឹងដឹងកុំអោយដូចជាម៉ែឪពុកនឹងចង់ចេះដឹងអីចឹងហើយវាលំបាកចឹងណា!
ចឹងអោយកូននឹងបានខំប្រឹងរៀនព្រោះអីថាម្តាយនឹងថាអត់សូវបានរៀនសូត្រអីនឹងគេ។
ចាសចឹងចង់អោយកូននឹងពេលទៅអនាគត់ទៅនឹងគេបាននឹងរៀនចេះអីនឹងចឹងទៅ។

ក៖
ចាស!ហើយទៅអ៊ីជាចុងក្រោយនឹងអ៊ីមានពាក្យពេជ្យសំរាប់នឹងបណ្តាំផ្ញើដល់ពួកគាត់ជាចុងក្រោយណាអ៊ី ជាចុងក្រោយអ៊ី?

ខ៖
ខ្ញុំគ្មានអីនឹងច្រើននោះទេខ្ញុំមានគ្រាន់តែថាអោយកូនចៅជំនាន់ក្រោយនឹងអោយបានរៀននឹងចេះដឹងនឹងចឹងទៅកុំអោយថាបឹងបាននឹងល្ងង់នឹងដូចជាខ្ញុំនឹងចឹងទៅណា។
ខ្ញុំនឹងគ្រាន់តែបាននឹងជូនពរអីនឹងតែប៉ុន្នឹងនោះទេព្រោះអីខ្ញុំនឹងវាគ្មានពាក្យអីច្រើនដើម្បីនឹងជូនពរ។

កៈ
ហឺ...កាលនឹងបើនិយាយទៅនឹងកាលពីសម័យមុននឹងមិនមែនមានតែអីនោះទេដែលថាមិនបានសូវរៀននោះ...

ខៈ វាមានច្រើនគ្នា។

កៈ
ចាស!ទើបតែដល់ពេលឥឡូវនឹងទេដែរក្មេងនឹងនឹងគាត់បានមានឧកាសទទួលបានការសិក្សានឹងបានច្រើន។

ខៈ នឹងហើយទើបតែក្មេងឥឡូវនឹងទេ
ហើយកាលនឹងពេលជំនាន់នឹងទៅរៀននឹងមិនទាន់នឹងមានកង់នឹងខោអាវណាទៅដើម្បីនឹងស្លៀកនោះទេ។
កាលនឹងនៅជំនាន់នឹងឪពុកម្ដាយរបស់ខ្ញុំនឹងគាត់គឺថាក្រនឹងគឺក្រអោយតែម៉ែនទែន។ ចាស

កៈ ចាស!

ខៈ
ហើយទៅចំណែកឯសំពត់នឹងពេលដែលបានសំរាប់នឹងយកទៅស្លៀកនឹងយកទៅបានតែ១នឹងទេសំរាប់ទៅរៀននឹងស្លៀកតែ១នឹងកាលនឹងហើយសំពត់នឹង១ទៅ២អាទិត្យអីនឹងបានបោក២ដង។ហើយកាលនឹងខ្ញុំនឹងមិនធម្មតានោះទេកាលនឹងព្រោះអីកាលនឹងខ្ញុំនិងបានដើរទៅនឹងមិនមែននឹងតិចជាគីឡូរនោះទេកាលនឹងពីនឹងទៅឯកោះដាច់ឯណោះ។
ពីនោះមកនឹងខ្ញុំដើរនឹងថាដើរហើយដូចថាពេលនឹងខ្ញុំនឹងអត់មានកង់ជិះនោះទេ
មានតែកង់មួយ....

កៈ កាលនឹងអីបានឈប់រៀនត្រឹមថ្នាក់អីប៉ុន្មានដែរកាលនឹង?

ខៈ កាលនឹងខ្ញុំបានឈប់រៀននឹងត្រឹមថ្នាក់ទី២
ព្រោះអីកាលនឹងខ្ញុំមានប្រវិត្តរបស់ខ្ញុំនឹងវាបានឈឺនឹងរហូតមកនឹង ខ្ញុំឈឺម៉ែរបស់ខ្ញុំនឹងឡើងក្រហើយកាលនឹងខ្ញុំឈឺនឹងតាំងពីខ្ញុំនឹងអាយុបាន៣ឆ្នាំដល់រហូតដល់ពេលដែលខ្ញុំនឹងមានអាយុបាន២១ឆ្នាំ ។
កាលនឹងការ១ខែទាល់១ខែហើយកាលនឹង១ឆ្នាំនឹងទល់នឹង១ឆ្នាំកាលនឹងខ្ញុំបានឈឺនឹងដោយសារតែខ្ញុំនឹងអត់មានរដូវកាលនឹង

ក៖ ហឺ...!

ខ៖ ចឹងកាលនឹងខ្ញុំឈឺនឹងទាល់តែខ្ញុំនឹងមានអាយុបាន២១បានជាខ្ញុំនឹងចាប់មានរដូវវិញ។
ខ្ញុំនឹងបានឈឺនឹងរហូតមករហូតចាប់ពីខ្ញុំនឹងមានអាយុ៣ឆ្នាំនឹងមក
ខ្ញុំឧស្សាហាឈណ៍ឈឺនឹងទាល់តែម្ដាយខ្ញុំនឹងក្រ។

ក៖ កាលនឹងអ៊ីនឹងបានឈឺនឹងកាលនឹងអ៊ីឈឺយ៉ាងម៉េចដែរកាលនឹង?

ខ៖
ខ្ញុំនឹងឈឺនឹងទាល់តែម្ដាយរបស់ខ្ញុំនឹងឡើងក្រខ្ញុំឈឺនឹងសាច់របស់ខ្ញុំនឹងគឺពណ៌ឡើងខ្មៅដូចសាច់សូត្រនេះចឹង!

ក៖ កាលនឹងឡើងស្រអាប់!

ខ៖
ចាស!កាលនឹងគឺថាវាឈឺរហូតឡើងខ្មៅស្លាំងតែម្ដងនឹងឡើងខ្មៅព្រោះអីកាលនឹងដូចថាវាអត់មានឈាមអីនឹងចឹងតែម្ដង។និយាយទៅកាលនឹងខ្ញុំគ្រួសាររបស់ខ្ញុំនឹងក្រក្រលែងលឺហើយក្រនឹង។

ក៖ ហើយដំពេលហើយនឹងវាបានល្អវិញនឹងនៅពេលដែលអ៊ីមានអាយុបាន២១ណ៎អ៊ី?

ខ៖ ចាស!ដល់តែពេលខ្ញុំបានអាយុបាន២១នឹងបានខ្ញុំចាប់ផ្ដើមវារាងស្រួលទៅនឹងវិញ។

ក៖ កាលនឹងអ៊ីបានលេបថ្នាំអីគេដែរកាលនឹងបានវាល្អវិញ?

ខ៖
កាលនឹងបងអើយកាលនឹងចេះតែមានថ្នាំអីនឹងក៏មានដែលហើយកាលនឹងម្ដាយរបស់ខ្ញុំនឹងបានអោយគេមកចាក់ហើយចេះតែមានថ្នាំអីគេខ្លះទេ
ព្រោះអីកាលនឹងគេនឹងចង់អោយកូននឹងបានជាព្រោះអីកាលនឹងហេតុតែខ្ញុំនឹងជាកូនដែលបងគេចឹងណាកាលនឹង។

ក៖ ចាស!

ខ៖
ហើយចឹងពេលដែលកូននឹងទើបតែមាននឹង១នឹងកាលនឹងហើយដល់ចឹងទៅកាលនឹងគាត់បានចេះតែទៅរកថ្នាំដោយសំរាប់នឹងបានចាក់ទៅមានទាំងថ្នាំដែលគេយកមកចាក់នៅនឹងក្បាល

ពោះនឹងក៏មាន
មានចាក់នៅអីផងចឹងក៏មានហើយដល់ពេលដែលបានចេះតែចាក់ៗនឹងចឹងទៅក៏មានអីក៏បានឈប់ចាក់។
ហើយចឹងពេលដែលកាលនឹងខ្ញុំមានហៀរមួយនឹងគាត់នៅឯភ្នំពេញនឹងគាត់បានប្រាប់ម្ដាយរបស់ខ្ញុំនឹងថាសឹងអើយសឹងឯងឈប់ចាក់ទៅ។
ហើយបើថាកូននឹងវាទាលទិញអីចឹងទៅទិញអោយវានឹងញ៉ាំចឹងទៅណា។
ដល់ពេលចឹងទៅមានតាឥស្សីនឹងសក់វែងហើយគាត់នឹងក៏បានអោយថ្នាំដល់ខ្ញុំនឹងបាន១គ្រាប់មក។

ក៖ ហឺស..!

ខ៖
រួចហើយកាលនឹងខ្ញុំនឹងខ្លាចតានឹងកាលនឹងខ្ញុំនឹងមិនហ៊ាននឹងលេបនោះទេកាលនឹងព្រោះអីថ្នាំនឹងដូចអាចម៍ពពែយើងនឹងចឹង។

ក៖ ចាស!

ខ៖
គាត់នឹងបានអោយដល់ខ្ញុំនឹងលេបហើយកាលនឹងគាត់បានប្រាប់ដល់ខ្ញុំនឹងថាគាត់នឹងអាចជួយបាននឹងតែ១នាក់នឹងទេ។
ចឹងគាត់នឹងបានអោយដល់ខ្ញុំនឹងបាន១គ្រាប់នឹងហើយគាត់ប្រាប់ថាលេបថ្នាំ១គ្រាប់នឹងទៅគេអោយរស់វិញហើយ គេនឹងអោយបានជាហើយរស់វិញហើយ។

ក៖ អូ...!

ខ៖ ចាស!

ក៖ ហឺ...

ខ៖
ចាស!កាលនឹងខ្ញុំនឹងបាននិយាយទៅនឹងអោយអស់នឹងទៅកាលនឹងខ្ញុំនឹងបានដេកស្រោតនោះទេកាលនឹង។
អាយុ២១នឹងកាលនឹងខ្ញុំនឹងបានដេកស្រោតនោះទេកាលនឹងព្រោះតែកាលនឹងយើងនឹងស្លៀកអីនឹងវាមិនកើតនឹងកាលនឹង។

កៈ ហឺ...

ខៈ
យើងនឹងស្លៀកអីនឹងវាមិនបានកើតនោះទេព្រោះអីកាលនឹងវាមានសុទ្ធតែឆ្អឹងនឹងកាលនឹងពេលដែលថាចង់ទៅអង្គុយអីនឹងទាល់តែមានម្ដាយនឹងគាត់ជាអ្នកដែលបានទប់។

កៈ ស្គម!

ខៈ ចាស!ឡើងស្គមស្គាំង
ហើយកាលនឹងក្បាលវិញនឹងឡើងកោរត្រងោអស់ហើយយកកន្លែងនឹងសំរាប់នឹងភ្ជួរសារ៉ូម។

កៈ ហឺ...

ខៈ ពេលដែលបាននឹកឃើញឡើងនឹងខ្ញុំបានឆែកចិត្ត
ខ្ញុំនឹងមិនបាននឹងនឹកស្មានថាខ្ញុំនឹងបានរស់ជាមនុស្សជាម្នាលវិញនោះទេ។
ហើយកាលនឹងចេះបានលេបថ្នាំ១គ្រាប់នឹងមកចេះបានរស់នៅអាយុ២១នឹងបានជាខ្ញុំនឹងចេះចាប់ផ្ដើមមានរដូវនឹងមក។
ហើយដល់ពេលដែលមានរដូវនឹងហើយចឹងមានមែនពិតតែកាលនឹងក៏វាចង់ងាប់នឹងចង់រស់អីនឹងតិចអស់អីវាចង់នៅចង់ទៅចឹងដោយសារតែយើងកាលនឹងវានៅខ្សោយហើយវាមកច្រើនពេក។

កៈ ចាស!មុនដំបូងចឹង!

ខៈ
ចាស!យើងនៅខ្សោយហើយវាបានមកច្រើនពេកចឹងយើងនឹងទៅជាបានអស់ពីខ្លួនឯងវិញចឹងទៅកាលនឹងយើងដូចថាចង់អស់ពីខ្លួន។

កៈ ចាសៗ

ខៈ ហើយដល់ពេលដែលបានមកនឹងវិញនឹងខ្ញុំនឹងក៏បានស្រួលខ្លួននឹងវិញ។

កៈ
ចាស!ហើយចុះកាលនឹងលោកតាឬស្សីនឹងគាត់មកដល់ឯផ្ទះនឹងតែម្ដងឬក៏អីនឹងបានទៅរក?

ខៈ ការនឹងគាត់នឹងបានដើរនៅតាមផ្លូវ ហើយពេលដែលគាត់នឹងបានដើរនៅតាមផ្លូវនឹង!

កៈ ហើយចុះកាលនឹងអ៊ីធ្វើយ៉ាងណាបានដឹងថាគាត់នឹងជាតាឬស្សី?

ខ៖ កាលនៅជំនាន់នឹងមានដូនជី១នាក់ទីងទីនេះគេមានធ្វើជាព្រៃនៅនេះទី ហើយចឹងនៅឯកន្លែងនឹងកាលនឹងគេបានធ្វើជាផ្ទះរបស់ដូនជី។

ក៖ សំរាប់អោយដូនជីនឹងនៅតែគាត់ាការនឹងមានតែម្នាក់ឯងទេ?

ខ៖ មិនមែនមានតែម្នាក់ឯងនោះទេកាលនៅក្នុងសម័យនឹងមានស្រីមានប្រុសលនឹងចឹងតែដំពេលគេ ..កាលនឹងលោកតាដូនជីនឹងគាត់បានស្លៀកសនឹងពាក់សនឹងចឹងដល់ពេលចឹងទៅគាត់នឹងមានពុកមាត់របស់គាត់នឹងមានគេកាន់។ ហើយដល់ចឹងទៅមានក្រមួនអីនឹងកាលនឹងគាត់ដូចជាមានសក់នឹងឡើងពយ។

ក៖ ហឺ....

ខ៖ ដល់ពេលចឹងគាត់នឹងបានអោយថ្នាំចំនួន១គ្រាប់នឹងមកថាយកទៅលេបទៅ គាត់អាចនឹងជួយសង្គ្រោះនឹងបានតែ១នាក់នោះទេព្រោះអីថាថ្នាំរបស់គាត់នឹងមានតែម្នាក់នឹងចឹង។ ចឹងហើយកាលនឹងគាត់នឹងបានអោយមក ដល់ពេលចឹងទៅកាលនឹងម្តាយរបស់ខ្ញុំនឹងគាត់ម៉ែរបស់ខ្ញុំនឹងគាត់មិនអោយលេបនោះទេកាលនៅជំនាន់នឹងព្រោះអីខ្លាចគេនឹងដាក់ថ្នាំបំពុលកាលនៅជំនាន់នឹង!

ក៖ ហឺស!

ខ៖ ដល់ពេលហើយទៅក៏បានលេបហើយចឹងក៏បានចាប់ផ្តើមមានរដូវនឹងមកនឹងមក ។ ហើយពេលដែលបានមានរដូវនឹងមកនឹងខ្ញុំនឹងវាទៅជាលែងឈឺហើយលែងចុងចាប់អីនឹងទៅទៀតចឹងណា។

ក៖ ហើយពេលដែលគាត់បានដើរនៅតាមផ្លូវនឹងអ៊ីបានហៅគាត់អោយមកមើលឬក៏យ៉ាងណាដែរកាលនឹង?

ខ៖ កាលនឹងគាត់នឹងបានដើរមកសូមយើងនឹងមើលតែម្តងកាលនឹង។ គាត់នឹងបានមកសុំយើងនឹងមើលតែម្តងហើយក៏ជា!

ក៖ អូ..!អស្ចារ្យមែស? តែឥឡូវនឹងបាត់គាត់បាត់ហើយឥឡូវនឹងអ៊ីណោស?

ខ៖ ឥឡូវនឹងបាត់គាត់ទៅណាបាត់ហើយគាត់នឹងស្លាប់យូរទៅហើយលោកតាឥឬស្សីនឹង។

ក៖ ចឹងកាលនឹងគាត់គឺជាអ្នកភូមិនេះដែរ?

ខ៖ កាលនឹងគាត់នឹងមិនបានដឹងថាគាត់នឹងនៅក្នុងភូមិណានោះទេកាលនៅជំនាន់នឹងនោះ។

ក៖ ចាស!

ខ៖ កាលនៅជំនាន់នឹងតែម្ដាយឪពុករបស់ខ្ញុំនឹងក៏គាត់មិនបានស្គាត់គាត់នឹងដែរ។

ក៖ ហឺ...

ខ៖ កាលនឹងថាគាត់នឹងគឺជាទេវតានឹងក៏ថាបានដែរ។

ក៖ កាលជំនាន់នឹងមានអ្នកកាន់គាត់?

ខ៖ ចាសកាលជំនាន់នឹងមានអ្នកកាន់គាត់។

ក៖ចាស!

ខ៖
គ្រែលោជាតិមុននឹងយើងបានធ្វើបុណ្យល្អទៅហើយគេបានព្រោះយើងនឹងអោយបានរស់ឡើងវិញអីចឹងទៅណា។និយាយទៅនឹងវាវែងឆ្ងាយណាស់តែគ្រាន់តែថាខ្ញុំនឹងមិនបាននឹងបំភ្លេចគុណថ្នាំ១គ្រាប់នឹងទេ។ទោះបីជាយ៉ាងណានឹងក៏ដោយ។ហើយសព្វថ្ងៃនឹងខ្ញុំនឹងបាននៅកាន់ជើងធូកដែរសំរាប់នឹងដាក់អោយដល់ទៅគាត់ព្រោះអីពេលខ្លះចឹងទៅពេលដែលខ្ញុំនឹងបានមានអាម្មរណ៍ថានឹងក្ដៅក្រហាលនឹងក្រហៃយអីនឹងចឹងទៅខ្ញុំទៅអុជធូកំប៉ុងជើងធូករបស់គាត់នឹងហើយ។ ចាសចឹងខ្ញុំសព្វថ្ងៃនឹងមាននៅកាន់កំប៉ុងជើងធូករបស់គាត់នៅលើផ្ទះនឹង។

ក៖ អូ ..អស្ចារ្យមែនទែនអ៊ី
ហើយចឹងតើអ៊ីមានប្រវិត្តដែលល្អដែលឬទេថាពេលដែលអ៊ីបាននឹកឃើញហើយនឹងវាបានធ្វើអោយអ៊ីបានសប្បាយចិត្ត?

ខ៖
អត់មានប្រវិត្តថានឹងសប្បាយយ៉ាងម៉េចនោះទេបងខ្ញុំនឹងមានប្រវិត្តកើតមកឡើងនឹងគឺថាវាពិកបាកឡើងនឹងរហូតនឹង។
ហើយបើថាខ្ញុំនឹងចង់ទៅណាអីនឹងទៅមិនកើតនោះទេព្រោះអីនៅក្នុងផ្ទះនឹងមានតែស្រីតែ១នាក់ទេដែលម្ដាយរបស់ខ្ញុំនឹងគាត់ពិការទៀតចាសចឹងទៅពេលដែលយើងនឹងចង់ទៅឯណាអី

នឹងវាពិបាកណាស់ព្រោះអីយើងត្រូវចេញទៅក្រៅអីនឹងគឺត្រូវទៅចោលគាត់។ហើយមួយទៀតនឹងគាត់នឹងនៅមានអាម្មរណ៍ថានឹងត្រូវធ្វើទុក្ខអីនឹងបាន១ម្តងៗអីនឹងដែរនឹងចឹងហើយយើងនឹងមិនអាចនឹងទៅចោលគាត់នឹងបាននោះទេ។

ក៖ អូ…ចាស!!

ខ៖
ហើយតាំងពីតូចរហូតមកនឹងដែលខ្ញុំនឹងបានដឹងក្តីមករហូតដល់របាក់នេះហើយនឹងខ្ញុំនឹងមិនដែលបានមានរស់ជាតិថាសប្បាយនឹងអីយ៉ាងណានោះទេ!!

ក៖ ហឺស…..

ខ៖
ពេលខ្លះទៅនឹងវាបានសប្បាយពេលដែលគេនឹងបានហៅទៅអីនឹងបានសប្បាយដែលប៉ុន្តែសប្បាយទាំងតឹងចិត្តណា។ ខ្ញុំនឹងពិបាកទាំងកាយនឹងពិបាកទាំងចិត្តនឹងណា!!

ក៖ ចាសអ៊ី!! ហើយអ៊ីកាលនៅពីក្មេងនឹងអ៊ីមានធ្លាបបានចូលចិត្តលេងល្បែងដែរឬទេ?

(មានសំលេងកូនក្មេងទៅលេងនៅខាងក្រោយហើយធ្លាក់ហើយលើពាងហើយអ៊ីអ្នកទិញផ្លែខ្វិននឹងក៏បានស្រែឡើងថា អូកូននរណាគេនឹង?)

ក៖ ចាសអ៊ី!!មុននឹងអាអូនគាត់បានធ្លាក់ចូលមាត់ពាង?

ខ៖ ចាស!គាត់បានធ្លាក់ហើយរអិលចូលទៅក្នុងមាត់ពាង។

ក៖ តែគាត់អត់មានអីណាអ៊ីហេស?

ខ៖ អត់អីនោះទេ។

ក៖
ល្អវិញមុននឹងខ្ញុំភ័យដែរមិញនឹងព្រោះអីងាកទៅមើលទៅឃើញមនុស្សព្រោះអីកាលមុនដំបូងនឹងខ្ញុំស្មានតែផ្លែខ្វិននឹងគឺវាបានជុះមក។
តែពេលដែលបានងាកទៅមើលនឹងឃើញមនុស្សនឹងឡើងភ័យតែម្តង!!

ខ៖ ហឺសៗៗ

ក៖ ចាស!អរគុណច្រើននៃការសំភាសន៍ថ្ងៃនេះអ៊ី!!

ខ៖ ចាស!អរគុណច្រើន!!